ពូច _ អ៊ុម

# វេយ្យាករណ៍ខ្មែរ



សំរាប់

## ថ្នាក់ បឋមសិក្សា

ពូច-អ៊ុម

សាស្ត្រាចារ្យ

# វេយ្យាករណ៍ខ្មែរ

សំរាប់ថ្នាក់

## មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

បណ្ណាគារ គីម សេង ភ្នំពេញ
លេខ ២២៣ វិថីប្រជាធិបតេយ្យ

បោះពុម្ពលើក ទី ៥ ចំនួន ២·០០០ ច្បាប់
ព.ស. ២៥១៥ គ.ស. ១៩៧២

រក្សាសិទ្ធិ

## សារបាន


មាតិកា — ទំព័រ

វេយ្យាករណ៍ (អក្សរ - ស្រៈ) ... ១
ព្យញ្ជនៈ ——— ២
អក្សរអឃោសៈ-ឃោសៈ-សិថិល ... ៣
ពួកអក្សរ ——— ៤
ស្រៈ ព្យញ្ជនៈបន្ថែម - វណ្ណយុត្តិ .... ៥
វិធីប្រើវណ្ណយុត្តិ ——— ៦
ពាក្យព្យញ្ជនៈ ផ្លាស់ប្ដូររូប ..... ១២
វិធីសាធ្យាយទំពាំមាត់ ——— ១៣
វណ្ណយុត្តិ-មេស្សត្រ (ព្រហ្មគិត) .. ១៤
ឥទ្ធិការនៃអក្សរ ——— ១៨
ព្យាង្គរបស់ពាក្យ ——— ១៩
ព្យាង្គតម្រួត ——— ២០
សំឡេងអក្សរអឃោសៈ - ឃោសៈ .. ២១
នាមក្រិត - កិរិយាក្រិត ——— ២២
នាម ——— ២៥
លិង្គរបស់នាម ——— ២៧
វចនៈ ——— ២៨
គុណនាម ——— ២៩
កិរិយាសព្ទ ឬ កិរិយា ...... ៣១
វិធីកាត់ពាក្យមានបន្តក់នឹងឥតបន្តក់ ៣៣
សព្វនាម ——— ៣៤
កិរិយាវិសេសន៍ ——— ៣៥
វិធីប្រើអាយតនិបាត ——— ៣៦


## សារបាន


មាតិកា — ទំព័រ

និបាតសព្ទ ——— ៤៦
សង្ខ្យា ឬ សង្ខ្យាសព្ទ ——— ៥២
បុព្វបទ ——— ៥៤
អាគម - ឧបសគ្គ ——— ៥៥
សម្ពន្ធ ——— ៥៨
សមាសនាម ——— ៧៥
ពាក្យកើតពីអក្សរ ឋ ទ្ឋ ឋ ស្ន ស្ត ស្ថ ៧៨
ព្យញ្ជនៈផ្លាស់រូបតែសព្ទតង់នៅដដែល ៨០
អាក្រក់អាចុំនៅគ្នារត់ ——— ៨២
សុភាទខ្សោយ បានសង្គ្រោះត្រី .... ៨៤
វិជ្ជាសម្បត្តិ ——— ៨៦
នាងកន្រ្តី ... វិទ្ធិសេន ——— ៨៧
សត្វមុងនឹងក្រើ ——— ៨៩
ស្ត្រីពីរនាក់ដណ្ដើមកូនគ្នា ——— ៩០
រឿងក្ដាឃ្មុំនឹងដើមពន្រ្ទ ——— ៩២
ឆ្មាស្រុកនឹងចាបពុក ——— ៩៤
ក្មេងនឹងដួកវត់នៅដៃ ——— ៩៥
រឿងសត្វបង្កួយ ——— ៩៧
អទិន្នបុព្វកៈ ——— ៩៨
ស្លូបក្រី ——— ១០០
ឆ្នូមង ——— ១០១
សៀវហាប់ហោះ ឬ ហាប់វិញ ... ១០២

# សេចក្ដីផ្ដើម និង ការយល់ព្រម

ការកើតឡើងជាវិធីអក្ខរៈនេះ ដោយសារខ្ញុំយកចិត្តទុកដាក់ ជាគំនិតរបស់ខ្ញុំជាទីស្រឡាញ់ ព្រោះការធ្វើនេះ គឺធ្វើដោយចិត្តឯង ពុំបានគិតគម្រាំងនឿយលំបាកឡើយ ។

វិធីអក្ខរៈនេះ រៀបតែនឹងបោះបង់ចោលអសារឥតការទៅ ហើយ ស្រាប់តែលោក អ៊ុម-ឈាងស៊ុន ទីប្រឹក្សាព្រះរាជ-អាណាចក្រ កាលលោកនៅជាចាងហ្វាងក្រសួងសិក្សាធិការ ក្រុងភ្នំពេញ លោកមានចិន្តារៀបចំវិជ្ជាខេមរភាសាឲ្យបានរៀបរយ ទើបលោកឲ្យខ្ញុំយកការដ៏តិចតួចនេះជូនទៅលោក ។

ក្បួននេះមានកំណើតជាដំបូងបំផុត របៀបវេយ្យាករណ៍ពុំបានជាប្រសើរណាស់ណាឡើយ តែខ្ញុំសូមថ្លែងគុណលោក អ៊ុម-ឈាងស៊ុន ជាទីបំផុតដោយសេចក្ដីដែលលោករាប់អានការតិចតួចរបស់ខ្ញុំមិនឲ្យសោះសូន្យ ។ លោកក៏បានចាត់ចែងឲ្យក្រុមវិទ្យាសាស្ត្រ ក្រសួងសិក្សាធិការ ពិនិត្យបោះពុម្ពផ្សាយតាមយេះណការ ពីឆ្នាំវកនស័ក ព.ស. ២៤៨៨ ម្ដងរួចហើយ ។

ដល់មកថ្ងៃទី១ ខែសីហា គ.ស. ១៩៥០ នេះ ពេជពុត្តខេមររដ្ឋ ក្រុងភ្នំពេញ បានទៅសុំសៀវភៅនេះអំពីខ្ញុំជាអ្នករៀបរៀង ដើម្បីនឹងយកទៅចាត់ចែងបោះពុម្ពចុះបម្រើដល់សិក្ខាកាម-កុលបុត្រ ដែលស្រេកឃ្លានការសិក្សាអក្សរសាស្ត្រខ្មែរ ជាវយកទៅសិក្សារៀនសូត្រឲ្យបានសម្រេចតាមបំណង ។

ខ្ញុំក៏បានយល់ព្រម អនុញ្ញាតឲ្យពេជពុត្តខេមររដ្ឋបោះពុម្ពសៀវភៅនេះ តាមសេចក្ដីត្រូវការ ដោយសេចក្ដីសង្ឃឹមថា អក្សរសាស្ត្រខ្មែរ នឹងបានឡើងកាន់តែខ្លួនធម៌លូតលាស់ដុះដាលរហូតទៀតទៅអនាគត ។

ព.ស. ២៤៩៣ គ.ស. ១៩៥០

ញូវ អ៊ុម

# វេយ្យាករណ៍ខ្មែរ

១ – វេយ្យាករណ៍ខ្មែរជាក្បួនបង្រៀនវិធីអក្ខរៈ ដើម្បីនិយាយត្រឹមត្រូវ សរសេរត្រឹមត្រូវក្នុងភាសាខ្មែរ ។ ក្បួនវេយ្យាករណ៍ត្រូវរៀបរៀងតាំងពីព្យញ្ជនៈ ។

អក្ខរៈ ឬអក្សរ ឬវណ្ណៈ មានពីរយ៉ាងគឺ: ស្រៈ ឬសរៈ និងព្យញ្ជនៈ ។ ស្រៈមានពីរពួក ស្រៈពេញតួ និងស្រៈនិស្ស័យ ។

ស្រៈពេញតួមាន ១៤ គឺ: អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ។

ស្រៈនិស្ស័យមាន ២០ តួគឺ ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។

ព្យញ្ជនៈមាន ៣៣ តួគឺ: ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ណ ត ថ ទ ធ ន ប ផ ព ភ ម យ រ ល វ ស ហ ឡ ° ។

ដែលហៅថាស្រៈពេញតួនោះ គឺស្រៈប្រើជាតួអក្សរដូចតួព្យញ្ជនៈដែរ ដូចពាក្យថា: ឥតគុណ ឥត ឥឡូវ ឦសាន ឧត្តម ឧស្សាហ៍ ឩទ្ទឹក ឩឡោក ឫក្ស ឫស្ស ឫទ្ធិ ឮទេ ? ឯក ឯនោះ ឰដ៏ ឰក ឱរ ឱដ្ឋ ឱស្ឋ ឳក ឳក់ ឳបម៍ ក្រៅ សារ ឥត ។

ដែលហៅថាស្រៈនិស្ស័យនោះព្រោះអាស្រ័យនឹងតួព្យញ្ជនៈទើបប្រើបាន ដូចពាក្យថា: កាម ដឹង ចុង កុង សូម លេង កាំបិត ប្រែង កន្តើយ ត្រើយ សម្បើម ចង់ពាញ ។



---

## ២ — ព្យញ្ជនៈ

ព្យញ្ជនៈមាន ៣៣ ចែកជា ៥ វគ្គបួនតួ ទីនិសេសវគ្គ ១ ។ វគ្គនិមួយៗ មានអក្សរ ៥ តួ, ឯសេសវគ្គមានអក្សរ ៨ តួ ។ វគ្គទី ១ គឺ: ក ខ គ ឃ ង ។ វគ្គទី ២ គឺ: ច ឆ ជ ឈ ញ ។ វគ្គទី ៣ គឺ: ដ ឋ ឌ ឍ ណ ។ វគ្គទី ៤ គឺ: ត ថ ទ ធ ន ។ វគ្គទី ៥ គឺ: ប ផ ព ភ ម ។

សេសវគ្គៈ យ រ ល វ ស ហ ឡ អំ ។

ព្យញ្ជនៈទាំងឡាយមានស័ព្ទសំឡេងជាពីរពួក ពួកសំឡេងតូចហៅថាអឃោសៈ ពួកសំឡេងធំហៅថាឃោសៈ ។

## អក្សរអឃោសៈ

ក ខ - ច ឆ - ដ ឋ - ត ថ - ប ផ - ស ហ - ឡ អ ។

## អក្សរឃោសៈ

គ ឃ ង - ជ ឈ ញ - ឌ ឍ ណ - ទ ធ ន - ព ភ ម - យ រ ល វ ។

អក្សរនៅចុងវគ្គទាំង៥ ទីងនៅចុងសេសវគ្គឈ្មោះនិគ្គហិតគឺ ង ញ ណ ន ម អំ ។ តួព្យញ្ជនៈទាំងឡាយមានសំឡេងប្លែកពីគ្នា: ខ្លះមានសំឡេងតែមួយ ខ្លះមានសំឡេងផ្សំ ។ តួដែលមានសំឡេងត្រៃតែមួយហៅថាសិថិល, តួដែលមានសំឡេងផ្សំហៅថាធនិត ។

## អក្សរសិថិល

ក គ - ច ជ - ដ ឌ - ត ទ - ប ព - យ រ ល វ ស ហ

ទីងនិគ្គហិតង ញ ណ ន ម អំ ។

## អក្សរធនិត

ខឃ - ឆឈ - ឋឍ - ថធ - ផភ ។

---

# ៣ — គូអក្សរ

ក្នុងវគ្គនិមួយ ៗ មានអក្សរជាគូគ្នាពីរគូ នោះគឺ:

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| វគ្គទី | ១ | អក្សរ | ក | ជាគូនឹងអក្សរ | ខ | ។ | គ | ជាគូនឹង | ឃ |
| " | ២ | " | ច | " | ឆ | ។ | ជ | " | ឈ |
| " | ៣ | " | ដ | " | ឋ | ។ | ឌ | " | ឍ |
| " | ៤ | " | ត | " | ថ | ។ | ទ | " | ធ |
| " | ៥ | " | ប | " | ផ | ។ | ព | " | ភ |

ឯអក្សរនៅសេសវគ្គជាគូសំប៉ិលទាំងអស់ ឥតមានគូទៀយ នឹងអក្សរនៅខាងចុងវគ្គទាំង ៥ ក៏ជាសំប៉ិលឥតមានគូដូចគ្នាដែរ ។ អក្សរឥតគូ ឬអក្សរគោលទាំងនោះគឺ ង ញ ណ ន ម យ រ ល វ ស ហ ឡ ំ ។

---

## ៤ — ព្យញ្ជនៈបន្ថែម

ដើម្បីនឹងប្រើការឲ្យគ្រប់គ្រាន់ក្នុងភាសា បុរាណាចារ្យលោកបន្ថែមព្យញ្ជនៈដោយថែមវណ្ណយុត្តិមូសិកទន្ត នឹងត្រីសព្ទលើព្យញ្ជនៈ ៩ ព្យញ្ជនៈទាំងនោះគឺ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ ប៊ ស៊ ហ៊ អ៊ ។ ព្យញ្ជនៈទាំងនេះបើកាលណាមានស្រៈនិស្ស័យ ិ ី ឹ ឺ ើ ភ្ជាប់លើគួរគេប្តូរវណ្ណយុត្តិ ៉ ៊ ជា ុ , ដូចពាក្យៈ បុិន មុឺន វុី បុី សុី ហុឹង អុី ។

---

## ៥ — វណ្ណយុត្តិ

សញ្ញាដែលបន្ថែមលើអក្សរៈ ដើម្បីនឹងលំអៀងសូរ្ទវែងជាសូរ្ទខ្លី ឬលំអៀងសូរ្ទឲ្យប្លែកពីសូរ្ទដើម ឬកាត់ពាក្យក្នុងប្រយោគជាសម្គាត់ដើម្បីឲ្យលះសេចក្តីហៅថាវណ្ណយុត្តិ ។ វណ្ណយុត្តិទាំងឡាយគឺ បន្តក់ ( ់ ) មូសិកទន្ត ( ៉ ) ត្រីសព្ទ ( ៊ ) សំយោគសញ្ញា ( ុ ) របាទ ( ៌ ) អស្តា ( ៏ ) ទណ្ឌឃាត ( ៍ ) វិសជ្ជនីយ ( ះ ) កុក្កុដនេត្រ ( ៖ ) កាកបាទ ( + ) វង់ក្រចក ( ( ) ) អញ្ញត្តិ ( « . . » ) លៈ ( ។ល។ )

(មកពីពាក្យបេយ្យាលៈ គេយកតែអក្សរ ល ពង់ចុង) តាមក្រុមបវរៈយោសាន (៤៥—) ខណ្ឌ (១)

---

## ៦–វិធីប្រើវណ្ណយុត្តិ

បន្តក់–សញ្ញានេះ សំរាប់ដាក់ថែមលើតួប្រកប ដែលព្យាង្គពាក្យកើតឡើងពីស្រៈ អ នឹងស្រៈ អា ហើយកាត់សំឡេងវែងជាសំឡេងខ្លី ដូចពាក្យៈ ចង សំឡេងវែង, ចង់ សំឡេងខ្លី; ចាក សំឡេងវែង, ចាក់ សំឡេងខ្លី, ឃាត សំឡេងវែង, ឃាត់ សំឡេងខ្លី ... ឯអក្សរជាតួប្រកបរបស់ព្យាង្គពាក្យ ហើយទទួលសញ្ញាបន្តក់ ( ់) បានមានតែអក្សរទាំងនេះ ក ង ច ញ ត ន ប ល ស ។ អក្សរក្រៅពីនោះទៅ ទោះកាត់សំឡេងវែងជាខ្លីក៏ដោយ មិនដែលទទួលវណ្ណយុត្តិបន្តក់ ( ់) ឡើយ ដូចពាក្យៈ ចខ បថ សត្វ កត ... ប៉ុន្តែបើពាក្យណាដែលចេញមកពីបាលីឬសំស្ក្រឹត ទោះអក្សរដែលត្រូវទទួលបន្តក់ ( ់) បាន ក៏គុំត្រូវដាក់បន្តក់ ( ់) ឡើយ ដូចពាក្យៈ កុសល ផល លាមធ ធនធាន ជន សត្វ ទត្ត ក្សេត្រ ។





មូសិកទន្ត – សញ្ញានេះ សំរាប់ថែមលើអក្សរនៅដើមព្យាង្គពាក្យ កាលណាពាក្យនោះគ្មានព្យាង្គឯទៀតបន្ថែមមក ឬព្យាង្គនោះពោលគឺដាច់តែឯង ដូចពាក្យ ប៉ុន្តែ ប៊ុណ្យឈឿន ម៉ក់ ញ៉ាំ ញ៉ី បើកាលណាមានស័ព្ទព្យាង្គដើម ឬតួអក្សរដើមបន្ថែមមក មិនត្រូវដាក់មូសិកទន្ត (") ឡើយ ដូចពាក្យៈ ប្រមោយ ស្រវឹង បម្យា បរិមុក ប្រមាទ សង្កាត កុង វិម ថ្ម គ្នាក .... ។

ត្រីស័ព្ទ – វិធីប្រើវណ្ណយុត្តិត្រីស័ព្ទ មានលំនាំដូចគ្នានឹងមូសិកទន្តដែរ ដូចពាក្យ: ទ្រហឹង ត្រហោ វិហារ ពហាន ។ ស៊ី ហ៊ឹងគ្រហៀក អ៊ុត ហ៊ាន ស៊ុន ស៊ើបការ ... ។

សំយោគសញ្ញា – វណ្ណយុត្តិនេះ សំរៀនស័ព្ទបាលី ឬសំស្ក្រឹតមកជាស័ព្ទខ្មែរ ។ ឧបមាដូចពាក្យៈ (ភយ) ភ័យ; (ជយ) ជ័យ; (ខយ, ក្សយ) ខ័យ, ក្ស័យ; (ពន្ធ) ព័ន្ធ; (ពទ្ធ) ព័ទ្ធ; (យន្ត, យន្ត្រ) យ័ន្ត, យ័ន្ត្រ; យន្ត (យន់), (សម្បទ) សម្ប័ទ, សម្បត្តិ; (បច្ចយ); បច្ច័យ (អាលយ) អាល័យ; (សមយ) សម័យ; (សំសយ) សង្ស័យ; (ហទយ, ហឫទយ) ហទ័យ, ហឫទ័យ ។

សញ្ញានេះប្រើនូវពាក្យខ្មែរខ្លះដែរ កាលណាពាក្យនោះមិនពេញលេញ ជាពាក្យកើតមកពីស្រៈ អ ឬ អា ហើយអក្សរជាគូប្រែគប ដូចពាក្យថាៈ ជ័រ ញ័រ ទំព័រ ទទ័ទរ ព្រឺព្រ័រ សាសទ័រ ញញាក់ញញ័រ ... ។

របាទ – សញ្ញានេះជំនួស រ កាលណា រ ជាជំនួសតួអក្សរគ្រួត ។ របាទ (៌) ជាវណ្ណយុត្តិសំរាប់ដាក់ នូវពាក្យសំស្ក្រឹតក្លាយមកពីបាលី ។ ជាធម្មតា តួអក្សរណាដែលពុំសូវប្រើជាជើងជាគ្រាក់ តួគ្រួតអក្សរនោះផ្លាស់ជារបាទ ។ បើតួអក្សរណា



ធ្លាប់ប្រើ ត្រាត់ក្នុងជើងជើង គួរប្រែតអក្សរនោះផ្លាស់ជាត្រាត់ ។ គួរប្រែតផ្លាស់ជា រ ក៏បាន ដូចមានពាក្យទាំងនេះជាបែបយ៉ាង ៖ ណ្ណ = ណ៌, ម្ម = ម៌, ត្ត = ត៌, ក្ក = ក៌, ពណ្ណ = ពណ៌, ធម្ម = ធម៌, គក្ក = គក៌, បុញ្ញ = បុញ៌, បរិបុណ្ណ = បរិបូណ៌ = បរិបូរណ៌ ។ មានអក្សរខ្លះដែលធ្លាប់មានជើងជើងត្រាត់ ជាប់ដោយសញ្ញាបាទខ្លះ ក៏មានដែរ ដូចពាក្យៈ គក្កដ ជា គក៌ដ; វិសជ្ជនីយ ជា វិសជ៌នីយ, មគ្គុទ្ទេស ជា មគ៌ុទេស, មគ្គ ជា មាគ៌, មារយាទ ជា មាយ៌ាទ ។

កំណត់កត់សំគាល់ - ក្ក = ក្រ, គ្គ = គ្រ, ទ្ទ = ទ្រ, ស្ស = ស្រ, ដូចពាក្យៈ បក្ក = បក្រ, ឧគ្គ = ឧគ្រ, មុគ្គ = មុគ្រ, សមុទ្ទ = សមុទ្រ... ប៉ុន្តែគួរអក្សរដទៃពីនេះ ដូចពោលខាងលើនេះមិនផ្លាស់គួរប្រែតជា "រ" ឡើយ ។

អស្តា– សញ្ញាអស្តា ប្រើដាក់តែលើអក្សរ ក និង ដ ហើយ ក និង ដ នោះជាពាក្យនិបាត គឺពាក្យនោះមិនមែនជានាម ជាគុណនាមឬជាកិរិយាសព្ទ ដូចពាក្យថា: ទោះហាមដូចម្ដេច ក៏គេមិនស្ដាប់ ។ អ្នកកាន់ព្រះធម៌ដ៏ប្រសើរ រមែងរួចផុតពីអបាយភូមិ ។ ប្រសើរដ៏ឧត្ដម ។

ក្នុងពាក្យឧទានសព្ទ គឺពាក្យថាដោយភ្ញាក់ផ្អើល សញ្ញានេះមានប្រើខ្លះដែរ ដូចពាក្យ: ឧហ៏ ! ឧន៏ ! ឱ៊ះហ៏ ឬឧន៏ ! ។

ទណ្ឌឃាត– ទីនិងបង់សេចក្ដីអក្សរលើសពីការ គេដាក់ទណ្ឌឃាត: រ័តន៍, ពោធិ៍, កេតុ៍, ប្រយោជន៍ . . . ។

វិសជ្ជនីយ – សញ្ញានេះប្រើជំនួសរបស់ "ស" ស័ព្ទខ្លះ: នេះ, ព្រោះ, ដះ.... ។

កុក្កុដនេត្រ– សញ្ញានេះ សម្រាប់ប្រើផ្ដើមសេចក្ដី ។

កាកបាទ– សម្រាប់ប្រើពាក្យឧទានសព្ទ និងពាក្យវិសេសនៃបព្វនាមខ្លះ ដូចពាក្យថា: ច៎ះ ! ចា៎ ! នុ៎ះ ។

វង់ក្រចក – សញ្ញាវង់ក្រចកសំរាប់ដាក់គៀបពាក្យណា ឬ ឃ្លាណាមួយ ដែលមិនមានទាក់ទងនឹងចូលក្នុងអត្ថបទនោះទេ គ្រាន់តែជាស័ព្ទពន្យល់ពាក្យណាមួយ ដែលមានក្នុងអត្ថបទនោះៗ ដូចពាក្យថាៈ បិតាខ្ញុំអញ្ជើញទៅប្រទេសថៃឡង់ដ៍ (ប្រទេសសៀម) តាំងពីខែមេសាម៉្លេះ ៗ

អព្ភន្តរៈ – សញ្ញាអព្ភន្តរៈ សំរាប់ដាក់គៀបឃ្លាណាដែលមានសារប្រយោជន៍ច្រើន ឬ ឃ្លាណាដែលអ្នកនិពន្ធចង់ឲ្យអ្នកអានយកចិត្តទុកដាក់ប្រឹងអានឃ្លានោះជានិច្ច ដូចពាក្យថា ខេមរជនហើយដឹងគ្រប់គ្នាថា "ចេះពីរៀន មានពីរក" ប៉ុន្តែមិនមានជនណាមួយ ខំអនុវត្តតាមពាក្យចំនៀមនោះសោះ ៗ

លៈ ៗ ល ៗ – សញ្ញាលៈ (ៗ ល ៗ) នេះ សំរាប់ប្រាប់ថា ពាក្យដែលគេរាប់រៀបនោះ មិនទាន់អស់ទេនៅមានតទៅទៀត ៗ

គោមូត្រ ឬ បរិយោសាន – សញ្ញានេះ សំរាប់បញ្ចប់សេចក្តីថា ស្រេចឥតមានតទៅទៀត ៗ

ខណ្ឌ – សញ្ញាខណ្ឌនេះ សំរាប់ដាក់សេចក្ដីសង្កាត់ៗ ដើម្បីធ្វើសេចក្ដីនោះឲ្យល្អស្អាត ។

## ៧ - អក្សរព្យញ្ជនៈផ្លាស់ប្ដូរ

ក្នុងអក្សរផ្លាស់ប្ដូរ កើតឡើងអំពីពាក្យបាលី ដែលក្លាយទៅជាពាក្យសំស្ក្រឹត ពាក្យទាំងនោះខ្មែរប្រើទាំងបាលីទាំងសំស្ក្រឹត ។ ន័យរបស់ពាក្យដូចគ្នា ៗ ស័ព្ទនិងរូបអក្សរដូចគ្នា ៗ ក្នុងផ្លាស់ប្ដូរទាំងឡាយនោះ នឹងសំរេចជាក្បួនដាច់ស្រេចពុំបាន មានក្បួនផ្លាស់ខុសរបៀបក៏មាន ប៉ុន្តែការផ្លាស់ភ្ជាញឹកញយនោះ ដូចមានពាក្យឧបមាទាំងនេះ អក្ខរៈផ្លាស់ជាអក្សរ, យក្ខៈ ជាយក្ស, រុក្ខៈ ជាវ្រឹក្ស, សិក្ខា ជាសិក្សា, ខត្តៈ ជាក្សត្រ, ខេត្តៈ ជាក្សេត្រ, ខេមៈ ជាក្សេម, ខណៈ ជាក្សណៈ, ខីរៈ ជាក្សីរ, និច្ចៈ ជានិត្យ, កិច្ចៈ ជាក្រឹត្យ, អាទិច្ចៈ ជាអាទិត្យ, វិនិច្ឆ័យ ជាវិនិស្ច័យ, អច្ឆរិយៈ ជាអស្ចារ្យ, បច្ឆិមៈ ជាបស្ចិម, វិជ្ជា ជាវិទ្យា, វេជ្ជៈ ជាវេទ្យ, សាមគ្គៈ ជាសាមគ្គ្យ សាមគ្រ្យ, មជ្ឈិមៈ ជាមធ្យម, ឈានៈ ជាធ្យាន, វឌ្ឍៈ

ជា ទេស្ឋ, អធិដ្ឋាន: ជាអធិស្ឋាន, ព្រះទុដ្ឋ: ជាព្រះទុស្ឋ ឋិត: ជា ស្ថិត, ឋាន: ជា ស្ថាន, ថន: ជា ស្តន, ព្រះហត្ថ: ជា ព្រះហស្ត, វត្ថ: ជាវស្ត្រ ៗ អត្ថ: ជាអាថ៌ . . . ចក្ក: ជា ចក្រ, បុត្ត: ជាបុត្រ, រត្តិ ជារាត្រី, មេត្តា ជា មេត្រី ៗ សមុទ្ទ: ជា សមុទ្រ, កន្ទប្ប: ជា កន្ទប៌, វេស្សវណ: ជា វៃស្រវណ, ធម្ម: ជា ធម៌, មគ្គ: ជា មាគ៌, បុព្វ: ជា បូព៌, បរិបុណ្ណ: ជា បរិបូណ៌ ឬ បរិបូរណ៍, បុណ្ណមី ជា បូណ៌មី, គព្ភ: ជា គភ៌, ទុគ្គត: ជា ទុគ៌ត ឬ ទុរគត, ៗ

## ៨_ វិធីស្វាធ្យាយន៍បាំមាត់

ត្ត ផ្លាស់ជា ត្យ, ច្ច ផ្លាស់ជា ត្យ, ច្ឆ ផ្លាស់ជា ស្ច; ជ្ឈ ផ្លាស់ជា ធ្យ, ជ្ជ ផ្លាស់ជា ទ្យ, ដ្ឋ ផ្លាស់ជា ស្ឋ; ត្ថ ផ្លាស់ជា ស្ត ៗ ក្ក កម្រែកជា ក្រ, ត្ត កម្រែកជា ត្រ, ទ្ទ កម្រែកជា ទ្រ ៗ ម្ម កម្រែជា ម៌, ណ្ណ កម្រែកជា ណ៌, ព្ព កម្រែកជា ព៌, គ្គ កម្រែកជា គ៌, ទ្ទ កម្រែកជា ទ៌, ក្ក កម្រែកជា ក៌ ៗ

មានពាក្យខ្លះកើតពីអក្សរ វ និង ព ផ្លាស់ប្តូរគ្នា ដូចពាក្យ ជា: វាច វាចា ជា វាក្យ ឬ ពាក្យ, វេលា វិលា ជាពេល,

វនៈ ជាពន (ព្រៃ), វរៈ ជា ព្រះ, វ្ឫក្សៈ ជា ព្រឹក្ស, វំសៈ ជា វង្ស ឬ ពង្ស, វិសាខៈ ជា ពិសាខ, វ្ឫហស្បតិ ជា ព្រហស្បតិ, វិញ្ញាណៈ ជា វិញ្ញាន, ហេមវន្តៈ ជាហេមពន្ត... ។

ពាក្យខ្លះទៀតដូច: សត្តៈ ជាសត្វ, សកវស្ស ជា សកវត្ស ឬ វត្សរ៍, ចៀវស្សៈ ជា ចៀវត្ស... ។

---

## ៩ – វណ្ណយុត្តិ – មេសូត្រ (ព្រហ្មគីតិ)

អ្នកអើយសិញ្ញា ត្រូវសិក្សាចេះឲ្យមុត
ឲ្យស្គាល់គ្រឿងវណ្ណយុត្តិ ចូរខំស្រាវគិតកំពើង ។

( ់ បន្តក់ )

សញ្ញាមួយនោះណា រាងរូបាទ្រង់ដូចស្ទឹង
បន្តក់វណ្ណយុត្តិហ្នឹង កាត់ស័ព្ទវែងជាស័ព្ទខ្លី ។

( ៉ មូសិកទន្ត )

ស្ទឹងពីរដាក់ទំមគ្នា លើអក្សរប្រែសំដី
ឈ្មោះមូសិកទន្ត ធ្មេញកណ្ដុរចូរចាំទុក ។

( ័ សំយោគសញ្ញា )

វណ្ណយុត្តិមួយនោះនៃ កដិចបមេឃដូចជាក្លុក
គជសារ "ង" នៅមុខ ហៅថាសំយោគសញ្ញា ។

( ៌ របាទ )

នោះជាវណ្ណយុត្តិ
គូសខ្នងជំនួស "រ"
ចេន់ដោយក្រពិក "ង"
ដូចលំនាំកក្រសារ ។



( ៏ អស្តា )

សញ្ញាមួយវិញនោះ អស្តាស្មោះកងកាយា
អ្នកប្រាជ្ញបញ្ញត្តថា ឲ្យប្រើលើ "ដ" ទិង "ក" ។

( ៍ ទណ្ឌឃាត )

ទណ្ឌឃាតសម្រាប់បង់ តួមួយអគ្គិនៃអក្ខរ
ដែលលើសពិសំតួថា តាមតម្រាគេគតពោល ។

# ១៦ – ថ្នាក់ មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

( ៈ វិសជ្ជនីយ )

វិសជ្ជនីយស-ញ្ញានោះរុញសព្ទជាអៈ ដូចប្រើពាក្យ “ពោះ” “ទ្វះ” “មោះ” “សោះ” “ព្រោះ” សឹងក្បៀសពីរ ។

( ៙ កុក្កុដនេត្រ )

សញ្ញារង់ក្នុងមាន់ ចូរកុំកាន់ក្នុងជួនវៃ
អ្នកប្រាជ្ញលោកតែងៗ ទុកជាដើមផ្ដើមសេចក្ដី ។

( + កាកបាទ )

កាកបាទរាងជើងក្អែក ជាចំណែកសញ្ញាពោល
បិតលើពាក្យតំនោល ដូចជា ចា៎ះ នុ៎ះ ណា៎នែ ។

( () វង់ក្រចក )

ពាក្យទ្វះគួរបង់សេច តែដោយហេតុលុបមិនបាន
ទោះហើយទុកឲ្យមាន ដាក់នៅក្នុងវង់ក្រចក ។

( “...” អត្តន្តរៈ )

សញ្ញាជាក្រោយនេះ នាមជាអត្តន្តរី
ប្រយ័ត្នពាក្យក្នុងនេះ ដែលគេប្រើញ្ញយល់ជាក់ស្ដែង ។

( ៘ លៈ )

មាតិកាសំដែងវែង     គេចាវែងទុកលៃពាក
ដាក់ប្រួមពាក្យនោះមក     តំណាងជាសញ្ញាលៈ ៗ

( ៚— បរិយោសាន )

បរិយោសានសោត     ឬគោមូត្រចប់សំដី
សំដែងរឿងអ៊ីៗ     ចូរយើងដឹងដោយចំពោភ័រ ៗ

( ៗ ១ណ្ហា )

វិ១ណ្ហាសញ្ញាកាត់     ជាសង្កត់ចាកស្លាក់ស៊ើ
ឲ្យសេចក្តីប្រសើរ     ឯរូបភាពដូចឈើព្រាន ៗ

( - យតិភង្គ )

សញ្ញាជាបណ្តាច់     ក្រោយសំរេចមួយនេះឯង
ភ្ជាប់ផ្ទាខកាត្យចាវែង     ដែលព្យាង្គបែកចេញពីគ្នា ៗ
វិៈឈ្មោះសញ្ញានេះ     ចូរចាំចុះកុំគង្វា
យតិភង្គទាមា     ដកាបនៅកុំបំភ្លាយ ៗ

---

## ១០-- មុខងារនៃអក្សរ

ពាក្យដែលយើងនិយាយមួយម៉ាត់ៗ នោះពាក្យមានគួអក្សរប្រកបក៏ពាក្យគ្មានគួអក្សរប្រកបក៏ហៅថាព្យាង្គ ព្យាង្គដែលមានអក្សរជាគួប្រកបសម្រាប់ព្យាង្គនោះ គឺជាទីផ្លាស់ប្ដូរគួប្រកបពុំបានឡើយ ។ ឧបមាដូចពាក្យ: មុខ-មត្ត-សព្វ សុខ-ជ្រាប-ទេព...: នឹងសរសេរ: មុក-មាក់-សប់-សុក-ជ្រាព-ទេត... ដូច្នេះវិញពុំបានឡើយ ។ ភាសាខ្មែរប្រជុំនៃភាសា ៣ គឺ: ភាសាអ្នកស្រុក, ភាសាបាលី និងភាសាសំស្ក្រឹត ។ វេយ្យាករណ៍ចែកមុខងារអក្សរត្រញ្ញាន:ដាច់ស្រឡះ នោះអក្សរជាគួប្រកបនូវពាក្យខ្មែរ សឹងជាអក្សរនៅដើមវគ្គគឺ: ក ច ដ ត ប ។ អក្សរប្រកបនូវពាក្យបាលីដែលប្រើក្នុងភាសាខ្មែរ ឬពាក្យសំស្ក្រឹតក៏សឹងជាអក្សរទី ២ ទី ៣ ទី ៤ ក្នុងវគ្គគឺ: ខគឃ ឆជឈ ឋឌឍ ថទធ ផពភ ។ ឯអក្សរនៅចុងវគ្គ និងអក្សរនៅសេសវគ្គគឺ: ង ញ ណ ន ម យ រ ល វ ស ហ ឡ ប្រើបានជាគួប្រកបនូវពាក្យខ្មែរ

ពាក្យបាលីនិងពាក្យសំស្ក្រឹតជាមួយគ្នា ៗ ន័យមួយវិញទៀត អក្សរទាំងឡាយដែលបាត់ជាតួប្រកបនូវពាក្យមកពីបាលីឬសំស្ក្រឹត អក្សរទាំងនោះមិនត្រូវមានសញ្ញាបន្តក់ថែមពីលើឡើយ ៗ ពោះពាក្យនោះមានសព្វគ្រប់ហើយ ដូចពាក្យ: សព សត្វ ផល កុសល ជន ធនធាន ពល ប្រាកដ សទ្ធ លាមក ជាដើម ៗ

---

# ១១ — ព្យាង្គរបស់ពាក្យ

តួអក្សរផ្សំគ្នា ឬតួនឹងស្រៈផ្សំគ្នា កើតឡើងជាពាក្យ ពាក្យទាំងនោះ ពាក្យខ្លះមានព្យាង្គតែមួយ ពាក្យខ្លះមានព្យាង្គ ២ ឬហៅពាក្យពីរព្យាង្គ ពាក្យខ្លះបីព្យាង្គ ពាក្យខ្លះមានព្យាង្គច្រើនទៀត ៗ ព្យាង្គពោលឬពាក្យព្យាង្គតែមួយ: ចាស់-នៅ-ទឹក-ថ្ងៃ-លេង ៗ ពាក្យពីរព្យាង្គ: លំនៅ-បំណាច-បន្ទា-សណ្តែក ... ៗ ពាក្យបីព្យាង្គ: បម្រាក់-បន្ទាប-កន្ទះឡន់ ... ៗ ពាក្យច្រើនព្យាង្គ: អម្ពិលអំពែក-ពោសាធុពោស-បេកនុគោះ-កជកិច្ចានុកិច្ច ៗ

---

## ១២ - ព្យាង្គតម្រួត

ពាក្យទាំងឡាយមានពាក្យខ្លះកើតឡើងពីព្យាង្គកាយ ខ្លះពីព្យាង្គតម្រួត ។ ព្យាង្គតម្រួតកើតពីពាក្យពីរព្យាង្គជាធម្មតា, កាលណាព្យាង្គទាំងពីរនោះ ព្យាង្គខាងដើមមានអក្សរប្រកប ហើយអក្សរប្រកបនោះ ជាអក្សរនៅក្នុងវគ្គជាមួយគ្នា នឹងពាក្យព្យាង្គបន្ទាប់ ហើយព្យាង្គទាំងពីរ បើញែកគ្នាចេញព្យាង្គមួយៗ គ្មានស័ព្ទប្រែ បើប្រែបានក៏ប្រែខុសសំនៅដូចពាក្យថា: សន្ទូច, បណ្ដើរ.. បើញែកថា សន់-ទូច, បន់-ដើរ នោះពាក្យនិមួយៗ គតស័ព្ទថាជាអ្វី ៗ និងតម្រួតពាក្យលុះតែអក្សរប្រកបរបស់ព្យាង្គដើម នឹងអក្សរព្យាង្គបន្ទាប់នៅត្រូវលំដាប់គ្នា គឺជាអក្សរទី ១ នៅលើទី ២, អក្សរទី ៣

នៅលើទី ៤, អក្សរទី ៥ នៅលើអក្សរទាំង ៤ ខាងដើមនៃវគ្គ ដូចពាក្យ ភិក្ខុ - ព្យគ្ឃ (ខ្លា) - អគ្គិ - សង្ខារ - បង្គាប់ - សង្ឃឹម - ចិញ្ចឹម - បញ្ជូម មជ្ឈិម - ដណ្ដើម - កណ្ឋប - កណ្ដាំង... ។



ឯអក្សរក្នុងពួកសេសវគ្គគឺ: យរលវ សហឡអ បើត្រូវពាក្យត្រួតតោះទឹងនៅក្រោមគ្នាៗបាន ដូចពាក្យ: អង្វរ - ពន្យល់ - បន្ល្រាក់ - បន្ទា - ពន្រ្លី - បណ្ហា - បញ្ហា... ។

## ១៣ - សម្លេងអក្សរ អឃោសៈ - ឃោសៈ

អក្សរដែលមានសម្លេងតឹងហៅថា អឃោសៈ អក្សរដែលមានសម្លេងធូរ ឬបន្លឺធំហៅថា ឃោសៈ ។ សញ្ញាដែលសំគាល់បន្ថែមលើតួព្យញ្ជនៈ ង ញ ប ម យ រ ល វ ស ហ ឡ អ ដើម្បីប្រែឲ្យគ្រប់គ្រាន់ក្នុងកា ហ នោះកាលណាព្យាង្គតែ ហើយព្យាង្គដើមមានស័ព្ទជាអឃោសៈ ឬជាឃោសៈ ក្បាន្ទខាងចុងកំនែសម្លេងទៅ

តាមត្រាគ្គីដែលមិនបាច់ថែមវណ្ណយុត្តិឡើយ ដូចពាក្យៈ សង្កាត-សម្ព-ប្រមាទ-សមា-ចម្បា-សាលា-កុមារ-ប្រវែង ចម្ងាយ-សន្យា-សន្ទុក-សញ្ញា-ប្រាជ្ញ-វិហារ-ទាហាន-ជំហាន-ជំហរ... ។ ព្យញ្ជនៈផ្សំដែលហៅថាផ្ញើជើងនោះ ជើងអក្សរដែលយកទៅផ្សំនឹងសម្លេងទៅតាមតួលើ តាមដោយស័ព្ទសម្លេងជា ឃោសៈ ឬជាអឃោសៈ មិនបាច់មានវណ្ណយុត្តិដូចគ្នា ។ ចូរមើលព្យញ្ជនៈផ្សំទាំងនេះ ក្ក គ្គ ក្វ ឃ្ក ក្ន គ្ន ឃ្ន ឃ្ឈ ប្ជ ផ្ជ ប្វ ផ្វ វ្វ ទ្វ ទ្វ ស្ន ស្ទ ក្រ គ្រ ប្រ ប្រ ស្រ គ្រ ទ្រ ព្រ ម្រ... ក្នុង, កើតឃ្ញុំ, គ្នា... ។

## ១៤ — នាមក្រិត-កិរិយាក្រិត

អក្សរជាតួនឹងគ្នាកនិវគ្គ-ពាក្យយារចេញពីពាក្យដើម ឬបែកចេញពីពាក្យដើមហៅថាកិតៈ ឬក្រិត ។ ពៅនៃពាក្យទាំងឡាយ សឹងបែកចេញទៅពីតួឯង ឬចេញទៅពីអក្សរជាតួដូចពាក្យៈ ឈ្នួញ បែកចេញទៅជាពាក្យ ចំនួញ, កោស ចេញ





ទៅជាខ្នោស, តាប ទៅជាឃ្នាប, ចាំ ទៅជាចំណាំ, ឆ្អិន ទៅជាចំអិន, ធ្ងន់ ទៅជាទម្ងន់, បួស ទៅជាផ្នួស, ពំនួន ទៅជាកន្ទួន, គិត ទៅជាគំនិត, កាត់ ទៅជាកំណាត់, ទើប ទៅជាទំនើប..។ លើកតែពាក្យខ្លះ ដែលវេយ្យាករណ៍ មានអធ្យាស្រ័យឲ្យប្រើដូចពាក្យៈ ដើរ ទៅជាថ្មើរ, ត្រង់ ទៅជាដម្រង់ ឬតម្រង់, ត្រូវ ទៅជាតម្រូវ ឬ ដម្រូវ, ប្រជុំ ទៅជាជំនុំ... កិរិយាដែលបែកទៅជានាម ហៅថាកិរិយាក្រិត ។ នាមដែលចេញមកពីកិរិយា ហៅថានាមក្រិត ឬហៅថាកិតនាមក៏បាន ។ កិតនាមខ្លះជាកិរិយា ផងជានាម

## ២១. ថ្នាក់មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន





ដូចពាក្យៈ អ្នកដើរ អ្នករែក អ្នកដេក អ្នកមក អ្នកបេះ អ្នកទៅ សឹងជាកត្តិកនាម ។

ជំនុំនៃពាក្យ- ពាក្យដែលយើងនិយាយ កើតឡើងពីស័ព្ទច្រើនយ៉ាង:

១- នាម ។ ២- គុណនាម ។ ៣- កិរិយា ។ ៤- សព្វនាម ។ ៥- កិរិយាវិសេសន៍ ។ ៦- និបាត ។ ៧- ឧទានស័ព្ទ ។ ៨- បរិវារស័ព្ទ ។

## ១៤ - នាម

សំដីដែលបំផែងនូវឈ្មោះ ជាគ្រឿងសំគាល់ឲ្យហៅបាន ដូចពាក្យថា: មនុស្ស-សត្វ-ដី-ទឹក-ខ្យល់-ឈើ-ចន្ទ-សមុទ្រ ៘ ពាក្យទាំងឡាយនោះហៅថានាម ។ នាមនាម មានពីរយ៉ាងគឺ: សាធារណនាម ១ អសាធារណនាម ១ ។

### សាធារណនាម



វត្ថុទាំងឡាយ ដែលមាន បែបសណ្ឋានដូចគ្នាប្រហែលគ្នា ជាសាធារណនាម ដូចពាក្យ ហៅថា "ផ្ទះ" វត្ថុឯណាដែល មានភាព បែបប្រហែលនឹង

គេហដ្ឋាននោះហៅថាផ្ទះដូចគ្នា ។ "ស្រែ" វត្ថុណាមានភាពដូចដី



នោះហៅថាស្រែដូចគ្នា ។ "ខ្លែ" សត្វឯណា មានភាពដូចគ្នាហៅថា ខ្លែ ។ "ដើមគាំង" ត្រូវមានភាពដូចដើមមាំនោះ ហៅថាដើមគាំង.. ។

ពាក្យហៅថា ផ្ទះ-ស្រែ-ខ្លែ-ដើមគាំង ជាសាធារណនាម ។

## អសាធារណនាម

នាមអ្វីសំកប់តែមនុស្សម្នាក់ សត្វមួយ ឬវត្ថុមួយផ្សេងម្នាក់ឯង ហៅថាអសាធារណនាម ព្រោះនាមនោះមិនចំពោះទូទៅឡើយ ដូចនាមថា: ភ្នំពេញ - មេគុង - ក្រចេះ - ស៊ីសុវត្ថិ - នរោត្តម . . . ឈ្មោះភ្នំពេញសំកប់តែក្រុងខ្មែរម្នាក់ឯង, ឈ្មោះមេគុងសំកប់តែទន្លេ នៅស្រុកខ្មែរនេះ, ឈ្មោះស៊ីសុវត្ថិ-នរោត្តម សំកប់តែរូបស្តេចដែលសុគតហើយនោះ ។

## ១៦-លិង្គរបស់នាម

តាមនាមទាំងឡាយមានភេទផ្សេងគ្នា ភេទរបស់នាមនោះហៅថាលិង្គ ។ លិង្គមាន ៣ យ៉ាងគឺ: បុំលិង្គ (បុំងលឹង), ឥត្ថីលិង្គ, នបុំសកលិង្គ ។ បុំលិង្គគឺភេទសំរាប់មនុស្សប្រុស សត្វឬវត្ថុឈ្មោល, ឥត្ថីលិង្គ គឺភេទសំរាប់សំគាល់មនុស្សស្រី សត្វឬវត្ថុញី, នបុំស-កលិង្គជាភេទសំគាល់មនុស្ស សត្វឬវត្ថុខ្ទើយ គឺភេទមិនមែនជាប្រុសឬជាស្រី ជាឈ្មោលឬញី ។ តាមដោយបញ្ញត្តិនៃក្បួនហោរ នាមរបស់មនុស្សប្រុស ងាររបស់មន្ត្រីសឹងជាបុំលិង្គ ។ នាមរបស់មនុស្សស្រី នាមរបស់ ស្រុក - ភូមិ - នគរ - វត្ត - ខេត្ត - សឹងជាឥត្ថីលិង្គ ។ នាមរបស់មនុស្សខ្ទើយជានបុំសកលិង្គ ។ ឯក្នុងល្បែងខ្លះ វត្ថុដែលជាគ្រឿងលេងសឹងជាឥត្ថីលិង្គ ដូចអង្គញ់-មេប្រុក... ។

លិង្គប្រើជាពាក្យសំរាប់ប្រុសស្រី ដូចពាក្យថា: មា - ឪ - តា - ពូ - ធំ - អយ្យកោ - បិតុលា - កុមារ - យក្ស - យក្ខ - ចោរ - ភទី - ភទន្ត - ភិក្ខុ - សាមណេរ - គោ - ពានរ... ជាពាក្យសំរាប់បុំលិង្គ ។ ដូចពាក្យ

ហៅថា មីង - ម៉ែ - យាយ - អយ្យិកា - មាតុច្ឆា - កុមារី - យក្សិណី, (យក្ខិនី) - ទេវី - ករិនី - ភិក្ខុនី - ភិក្សុណី - សាមណេរី - នារី - ពានរី ព្រាហ្មណី... ជាពាក្យសំគាល់ឥត្ថីលិង្គ ។

---

## ១៧ វចនៈ

វចនៈ ជាពាក្យសំគាល់វត្ថុតែមួយ ឬវត្ថុច្រើន ។ ពាក្យដែលតំណាងវត្ថុតែមួយហៅថាវចនៈ ។ ពាក្យដែលតំណាងរបស់



ច្រើនហៅថាពហុវចនៈ ។ ក្នុងវចនៈទាំងពីរ យ៉ាងមិនជាការសំខាន់ពេកឡើយ, កាលណាគេចង់ប្រើជាពហុវចនៈ គេផ្ទួនពាក្យ ឬ ថែមពាក្យទៀតដូចជា: ប្រុស ៗ ស្រី ៗ ក្មេង ៗ កូនទាំងឡាយ ឈើទាំងឡាយ អស់ទាំងសត្វ ។ តែមានពាក្យខ្លះ ដែលចេញពីបាលី ឬ សំស្ក្រឹត មានសំគាល់វចនៈខ្លះដែរ ដូចពាក្យថា: រុក្ខ - រុក្ខា, យក្ស - យក្សា . . . រុក្ខ (ឯកវចនៈ), រុក្ខា (ពហុវចនៈ), យក្ស ( ឯក ) យក្សា ( ពហុ. ) ។

## ១៨ – គុណនាម

ពាក្យដែលសំដែងលក្ខណៈរបស់នាម ឲ្យធ្វើនាមឲ្យមានបទ ដូចពាក្យថា: ថ្មរឹង - មនុស្សចាស់ - ដែកស្អិត - កែវស្រួយ ... រឹង ចាស់ ស្អិត ស្រួយ ប្រាប់លក្ខណៈ ថ្ម - មនុស្ស - ដែក - កែវ ហៅថា គុណនាម ។ នាមនាមមានលក្ខណៈសម្រេចហើយ ហៅថា



គុណបទ ។ គុណនាមមានបីយ៉ាងគឺ: បកតិគុណនាម ១, វិសេសគុណនាម ១, អតិវិសេសគុណនាម ១ ។

## បកតិគុណនាម

គុណនាមសំដែងលក្ខណៈតាមលំនាំជាប្រក្រតី ដូចពាក្យថា: ភ្នំធំ - ទន្លេវែង - ស្លឹកស្ដើង - រនុំមូល - ដីខ្ពស់ - សេះធាត់ - សំពត់ម៉ដ្ឋ ស្រះរាបគប - ការទ្រុ - ក្ដារក្រាស់ - ប្រាក់រៀលសំប៉ែត - ក្មេងចាប គោស្គម - មនុស្សកំសោយ - ជាងប្រសប់ - កញ្ចាល់ស្ដៀង - សក់ក្រួញ -

ផ្ទះធំ - ខ្មៅស្រគាល - ព្រានពោត - ភ្លើងក្ដៅ - ទឹកត្រជាក់ - ខ្យល់ដោ- ក្បួនក្ដី - គុរលោង ខ្លាកាច ... ។

## វិសេសគុណនាម



គុណនាមដែលសំដែងលក្ខណៈរបស់នាមឲ្យវិសេសឡើង ដូចពាក្យថា: ផ្លូវត្រង់ជាង - ខ្លានេះកាចជាង - គោនេះធំជាង - មនុស្សប្រសប់ជាង - កាំបិតមុតជាង - ឈើខ្ពស់វែង ... ។

## អតិវិសេសគុណនាម

គុណនាមដែលសំដែងលក្ខណៈឲ្យវិសេសបំផុត ដូចពាក្យថា: បណ្ឌិតផុត - កំពោះសក្បុស - ស្បែកខ្មៅមាំ - កាំបិតមុតណាស់ - គោយើកណាស់ - កូនមនុស្សក្រាហ័ណាស់ ... ។

# ១៩ - កិរិយាស័ព្ទ ឬកិរិយា

ពាក្យពោលនូវអំពើធ្វើ ឬពោលនូវដំណើរជាអ្វី ហៅជា កិរិយាស័ព្ទ ដូចពាក្យថា: ដើរ - ឈរ - អង្គុយ - ដេក - ស៊ី - ផឹក - ទ្វូត-លាង - និយាយ - ស្តី - ហៅ - យំ - ស្រែក - វាយ - ដំ - ដក - គាប់ - ឈូស - ចាំង - ភ្ជួរ - ភស់ - កាប់ - កាត់ - អាន - សរសេរ - គិត - ធ្វើ ... ។



ពាក្យជាកិរិយាស័ព្ទ មានប្រធាន កាលណាគេបង្កើតជាប្រយោគដូចពាក្យ ថា: ខ្ញុំដើរ... ខ្ញុំជាប្រធានរបស់កិរិយាដើរ ។ យើងដេក - គេឈូស - វាធ្វើ - កូនសិស្សសរសេរ - អ្នកស្រែភ្ជួរ ... ។ កិរិយាមានពីរយ៉ាង គឺ: សកម្មកិរិយា ១, អកម្មកិរិយា ១ ។

## សកម្មកិរិយា

គេហៅថាកម្មគឺពាក្យដែលប្រើសំរាប់បំពេញអំពើរបស់កិរិយា គេ ហៅថាសកម្មកិរិយាគឺកិរិយាដែលត្រូវមានពាក្យមកបំពេញអំពើទើប

# ៣២ - ថ្នាក់ បង្គើមបន្ទាន់ នឹង ទុតិយបន្ទាន់



គ្រប់គ្រាន់ដូចពាក្យថា: ខ្ញុំឈូស ឈើ, គេទិញសំពត់, អ្នកនេសាទ ស្ទូចត្រី, ចោរលួចខ្សែ... ។ ឈើ- សំពត់ - ត្រី - ខ្សែ ជាកម្មរបស់ កិរិយា ឈូស - ទិញ - ស្ទូច - លួច ។

## អកម្មកិរិយា

កិរិយាដែលមានអំពើគ្រប់គ្រាន់នឹងខ្លួនឯងហើយ ហៅថា អកម្មកិរិយា ដូចពាក្យថា: ខ្ញុំកើត, ឈើធំទៅ, វាស្លាប់, កប៉ាល់ចេញ, ឪខ្ញុំមក, ប្អូនខ្ញុំដល់, ឈើឆាប់, សត្វហើរ, គេឈរ, ទឹកហូរ, គោដួល,



ផ្កាល្អ, គោដេក, ព្រាបថ្ងូរ, ខ្លាគ្រហឹម, សំពត់ជ្រុះ, លោកមានប្រសាសន៍ ... ។

កិរិយាមានឈ្មោះហៅថា ហេតុកិរិយា គឺកិរិយាដែលធ្វើអំពើទៅគេ ដូច ពាក្យថា: បង្រៀន គឺធ្វើអំពើទៅគេ ។

កិរិយាហៅថាសុទ្ធកិរិយា គឺកិរិយាដែលធ្វើចំពោះខ្លួនឯង ដូចពាក្យថា: រៀន គឺធ្វើអំពើចំពោះខ្លួនឯង ។

## ២០-វិធីហាត់

ពាក្យមានបន្តក់- កង់ កក់ កប់ ខ្លី ទល់ សក់ យល់ ពន់ ទក់ ឆន់ បក់ បង់ បង់ ហត់ ព្រនង់ កំពង់ ពន្យល់ ទំនប់ កញ្ចក់ បង្កង់ ដំទង់ គំរប់ ទំរង់ ចំណង់ កន្សល់ បង្អស់ បន្តក់ បំរត់ បន្ទប់ សំណល់ កញ្ចក់ កាត់ ខាត់ សាត់ ចាត់ ផាត់ ភឹត់ ហាត់ ឆាក់ ណាក់ បង្ហាត់ បំបាត់ សំខាន់ សម្លាប់ សំគាល់ កំណាញ់ បន្ទាល់ ក្បាល់ ទំនាស់ ប្រញាប់ប្រញាល់ កន្តាល់ អ៊ាន់ ហោក់ បំឡាក់ ស្រកន់ ប្រញាប់ ណាស់ កំចាត់កំចាយ ។

ពាក្យឥតបន្តក់- កល កុសល ផល គន្ធ គណ ចក្ក ឆត្ត គជទន្ត ជនបទ ជយ ចលបថ កម្មបថ ចលយាន ខណ្ឌ បញ្ញា បញ្ញត្ត បញ្ចកោណ និម្មល ពលកាយ កក្រ កត្តកាល

កាលបក្ស ប្រាកដ ប្រយ័ត្ន ប្រកព បក្ខគណនា មណ្ឌប ឥមល មាណព វក្ខ វក្ស ក្សត្រ ហរិវក្ស ។

---

## ៦១ - សព្វនាម

សព្វនាមជាពាក្យតំណាងនាម ដូចពាក្យថា: ខ្ញុំ, អ្នក, ឯង, វា, គេ, នាង, លោក, ព្រះអង្គ ... ជាសព្វនាម ។ សព្វនាមមានពីរយ៉ាងគឺ បុរិសសព្វនាម ១, វិសេសនសព្វនាម ១ ។

### បុរិសសព្វនាម

បុរិសសព្វនាមចែកជា: បឋមបុរិសៈ, មជ្ឈិមបុរិសៈ, ឧត្តម-បុរិសៈ ។ បឋមបុរិសៈគឺ: វា, គាត់, គេ, នាង, លោក, ព្រះអង្គ ... ។ មជ្ឈិមបុរិសៈគឺជាសព្វនាមសំរាប់ប្រើជំនួសឈ្មោះបុគ្គល ដែលគេកំពុងតែនិយាយទៅរកក្នុងចំពោះមុខ ហើយនិយាយមិនចេញឈ្មោះឡើយ យកសព្ទនេះជំនួស ដូចពាក្យចំពោះមុខ: ឯង, លោក, អ្នក, នាង, អា, ហង ... តាមពាក្យទាប-ខ្ពស់-កណ្ដាល ។ ឧត្តមបុរិសៈគឺ: ខ្ញុំ, ខ្ញុំបាទ, ខ្ញុំឯង, អញ, អញខ្ញុំ, អាត្មាភាព, យើងខ្ញុំ,

យើង... តាមពាក្យថា ប-ខ្ពស់-កណ្ដាល ។ ឧទាហរណ៍: កូនខ្ញុំបានអាយុ.. ដឹងក្ដីបន្តិចហើយ ឥឡូវនេះនាំទៅរៀនឯសាលា ។ មារបស់ខ្ញុំនៅភូមិឯស្រុកស្រែ គាត់បានឲ្យដំណឹងមកថា: គាត់នឹងមកលេងនឹងខ្ញុំនៅថ្ងៃខាងស្អែក ។



សត្វពាហនៈគឺ: គោ-ក្របី-ដំរី-សេះ, សត្វទាំងនោះត្រូវប្រយោជន៍ឲ្យយើង ចូរយើងថែរក្សាឲ្យល្អ ។ ទេវីម្នាក់ឈ្មោះបទុមកេសរ រត់ចេញពីនគរជាមួយនឹងស្វាមីទៅដល់កណ្ដាលព្រៃ នាងក៏ប្រសូតបុត្រ ។ ហ្វូងយានមកប្រថាប់ក្នុងបុណ្យនេះ ទ្រង់នឹងយានមកដោយយានសិវិកា, នាម៉ឺនសព្វមុខមន្ត្រីនៅចាំថ្វាយបង្គំព្រះអង្គ ។



អ្នកអញ្ជើញទៅកំពត នោះអ្នកនឹងទៅដោយអ្វី? ។

កាលណាឯងទៅនៅទីក្រុង ឯងកុំដើរលេងយប់ ឯងកុំមានកៀន នឹងមនុស្សអាក្រក់ ។ អាឯងឈ្មោះអ្វី? អាដែលលួចគេប៉ុន្មានដងហើយ? អាឯងមានប្រពន្ធកូនឬនៅ? ។ នៅថ្ងៃទំនេរពីថ្ងៃរៀន, ខ្ញុំធ្លៀតទៅសួរសុខទុក្ខម្ដាយរបស់ខ្ញុំ ។ ល្ងាចនេះគេនិមន្តគាត់ គាត់ទៅទេសនា ។ យើងរាល់រូប តែងតែមានសេចក្ដីស្លាប់ជាធម្មតានឹងជៀសពុំបាន ។

## វិសេសនសព្វនាម

វិសេសនសព្វនាម គឺជាសព្ទសំរាប់ប្រើជាជំនួយនាមនាមមានលំនាំជាបទវិសេសនៈ ដើម្បីនឹងមិនឲ្យប្រឡំសេចក្ដីក្នុងសង្កាត់នៃប្រយោគមួយៗ ។ វិសេសនសព្វនាម មានពីរយ៉ាងគឺ: វិសេសន-សព្វនាមនិយម១, វិសេសនសព្វនាមអនិយម១ ។ វិសេសនសព្វនាមដែលសំដែងសេចក្ដីដាច់ស្រេចហៅជានិយម ។ វិសេសនសព្វនាមដែលសំដែងសេចក្ដីមិនដាច់ស្រេចហៅជាអនិយម ។

វិសេសនសព្វនាមនិយម: នោះ, នុះ, ហ្នឹង, នេះ, មាក់, មួយទៀត, ឯនេះ, ឯណោះ ( Pronom démonstratif ) ។

វិសេសនសព្វនាមអនិយម: ឯណា, ដទៃ, ណាមួយ, ផ្សេង, ទៀត, ដូចម្ដេច, ពួកខ្លះ, អ្នកខ្លះ, ខ្លះ, ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, អ្នកណា, អ្វី, ឯទៀត ( Pronom indéfini ) ។

វចនសព្វនាមឯកវចនបឋមបុរិស: វា, គេ, នាង, លោក, ព្រះអង្គ, អា, មេ ... ។ ពហុវចនបឋមបុរិស: វាទាំងឡាយ, គេទាំងឡាយ, អស់នាង, អស់លោក ... ។

ឯកវចនមជ្ឈិមបុរិសសព្វនាម: អ្នក, នាង, លោក, ឯង, អា, ហង ... ។

ពហុវចនមជ្ឈិមបុរិសសព្វនាម: អស់អ្នក, អស់នាង, អស់លោក, ឯងទាំងអស់គ្នា, អាទាំងឡាយ ... ។

វចនឧត្តមបុរិសសព្វនាម: ខ្ញុំ ( ឯក. ), យើង ( ពហុ. ), យើងខ្ញុំ ( ពហុ. ) ។

វិសេសនសព្វនាមក៏មានវចនៈដូចពាក្យថា: នេះ ( ឯក. ), នោះៗ ( ពហុ. ), ណា ( ឯក. ), ណាៗ ( ពហុ. ), ម្នាក់ៗ ( ពហុ. ) ។

## ២២ - កិរិយាវិសេសន៍

កិរិយាវិសេសន៍ជាស័ព្ទបន្ថែមលើកិរិយា ដើម្បីឲ្យកិរិយាមានស័ព្ទ វិសេសឡើង ឬប្លែកឡើងទៀត ។ កិរិយាវិសេសន៍បន្ថែមស័ព្ទរបស់ គុណនាមឲ្យប្លែកឡើងដែរ ដូចបានអធិប្បាយរួចហើយនៅខាងលើ អំពីអតិវិសេសគុណនាមនេះឯង ។ បើកាលណាគេញែកពាក្យក្នុង បទសម្ពន្ធនោះគុណនាមនឹងកិរិយាវិសេសន៍បង្កាប់គ្នាជាបទ ហើយ ហៅជាអតិវិសេសគុណនាមក៏បាន ឬហៅញែកពីគ្នាចេញក៏បាន ។

កិរិយាវិសេសន៍ទាំងឡាយគឺ ឆាប់, ណាស់, យឺត, លឿន, មួយៗ, រឿយៗ, ទន្ទឹន, ណឹមណុម, ឋិតថេរ, ស្ទើរ, ទើះ, ក្បែក, ក្បាម, ថ្ងៃ, គាន់គាប់, ខ្ជាន់ខ្ជាប់, ញើបៗ, លបៗ, ណោះណោះ, គគាក់គគាំ, ទឹង, ខែលខល, ដកប, នៅ, បណ្ដាប់, បន្ដោក, បន្ទុប, បន្តិច, បន្ថែម; ញ៉ាបៗ, ប៊ុក, ប្រកិត ប្រកឹង, តួង, ស្រួស, ព្រួត, ព្រងើយ; រម៉ាំងរម៉ាក, គ្រែង, ប្រួង, ព្រឹច, ប៉ុង, គ្រាំង, គឹង... ។

ឧទាហរណ៍ ៖ ទៅចាប់, មកក្តាម, ដើរយឺត, មើលខាន់ខ្ទាប់, ធ្វើមារយាទប្រឹមប្រុម, មានដំរិតបិតថេរ, វេញប្រកិត, ប្រកឹងតារ, ដួលត្តូង. ទៅរម៉ាំងរម៉ោក, រលំគ្រឹង, ទៅណេះ, ទៅណោះ. មកជកប, ដម្លឹងពុំទាន់ជាទៅឡើយ, និយាយប៉ោចៗ, ដាក់ប៉ុក, រៀបចន្ទុប, អ្នកចិញ្ចឹមកថ្ងៃបន្តិចហើយ, ដើរតែលឿនស្ទើរ ... ។

---

## ២៣ - វិធីប្រើអាយតនិបាត

អាយតនិបាត មានអត្ថប្រព្រឹត្តទៅតាមចំនងសេចក្តី ដូចមានតទៅ ៖

អាយតនិបាតទី ១ - "រឺ" សំរាប់ប្រើជាបទប្រធានឬដើមបទ ។. រំពុណ្យវិធីបាប អំពើសុភាព នោះពាំតែងតាម... ។ រំព្រួបាត្យាយ ប្រដូចខ្សែទ្ធាយ អាត្មកឯងហោង ។ រំអំពើជាកុសលផលគប្បីធ្វើ ។

អាយតនិបាតទី ២ - មានអត្ថ ៤ យ៉ាង៖

១ - "ឆ្នូរ" សំរាប់ភ្ជាប់កម្មរបស់កិរិយាសកម្ម ។

ឧទាហរណ៍: គេស្តាប់នូវធម៌, សង្ឃសំដែងនូវធម៌ ។ ប៉ុន្តែក្នុងភាសាដែលគេនិយាយជាធម្មតា គេច្រើនកាត់ពាក្យ "នូវ" ដូចគេនិយាយថា: គេស្តាប់ធម៌, លោកសំដែងធម៌ ។

២– "កាន់" សំរាប់ភ្ជាប់កម្មទៅកិរិយាសកម្ម ឧ. គេទៅកាន់ផ្ទះ, វាមកកាន់ផ្ទះ ។ ប៉ុន្តែតាមភាសាធម្មតាគេច្រើននិយាយកាត់បន ដូចជា: ខ្ញុំទៅផ្ទះ, គេមកផ្ទះ ។

៣– "ញាំង" ជាទីទទួលសម្រេចនូវអំពើដែលគេឲ្យធ្វើ, ឧ. ពពួកសត្វផង សាហាវយង់ឃ្នង ប្រយ័ត្នញាំងបាន . . : ព្រះពុទ្ធត្រាស់ដឹងនូវអរិយសច្ច ហើយញាំងអ្នកដទៃឲ្យត្រាស់ដឹងផង, គ្រូប្រដៅទូន្មានសិស្សញាំងសិស្សឲ្យរៀន ។

៤– "អស់" ប្រែថាទៅ រហូតដល់, ឧ. គេទៅអស់យោជន៍បី, វាទៅអស់យប់មួយ ។

៥– "នឹង" ឬ "ចំពោះ" ទទួលពាក្យដែលគេនិយាយចំពោះខ្លួន, ឧ. ខ្ញុំបាននិយាយនឹងអ្នក, - ចំពោះអ្នក, គេផ្តាំមកនឹងខ្ញុំ ។

## អាយតនិបាតទី ៣– មានអត្ថ ៦ យ៉ាង:

១– "ដោយ" ជាគ្រឿងសម្រេចនូវអំពើ ។. គេធ្វើនូវអំពើដោយកាយ ។ គេកាន់ស៊ីៗដោយដៃ ។

២– "ដោយនូវ" ឬ "តាម" ឬ "ដោយសារ" ជាផ្លូវជាលំនាំដែលប្លែកពីការសម្រេចនូវអំពើ ។. ព្រះពុទ្ធទ្រង់យាងដោយនូវតេជះ, ធ្វើតាមពាក្យនៃអញ, រស់នៅដោយសារសេចក្ដីទំនុកបំរុងនៃខ្ញុំ ។

៣– "គឺ" ឬ "ដែល" ជាអ្នកសម្រេចនូវអំពើអំពីខ្លួនឯង ។: ធម៌គឺការៈដែលទ្រទ្រង់, ពាក្យនេះដែលខ្ញុំបានប្រាប់ហើយ, គឺអ្នកឯងមិនត្រូវធ្វើយ៉ាងនេះទៀត, ព្រះសាស្ដា គឺអ្នកទាំងឡាយគប្បីឲ្យអត់ទោស ។

៤– "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ជាហេតុ, ជាចំនង, ជាដំណើរ ។. បានជាគាត់នៅក្នុងទីនោះ ព្រោះតែសក្ការៈ, សត្វលោកមានចិត្តខ្ពស់ឡើងព្រោះលាភ មានចិត្តទ្រោមចុះព្រោះឥតលាភ ។

៤- "មាត" ជាអាការៈ ឧ. បើបុគ្គល មានចិត្តគិតទោស ប្រទូស្តហើយ ពាលក្តី ធ្វើក្តី... ។

៥- "ដោយ" ប្រកបជាមួយ ឧ. ប្តូរព្រមព្រៀងមួយ អន្ទើ ដោយដំណើរនោះ ។

## អាយតនិបាតទី ៤ – មានអត្ថ ៣ យ៉ាង:

១- "ដល់" ជាទីទទួលនូវកំណាយ ឧ. ចាយកឲ្យនូវទាន ដល់សង្ឃ, គ្រលំបាកឲ្យផល ដល់អ្នកកំដិល ។

២- "ដើម្បី" ឬ "បំរុង" ជាទីផ្ញើ·បញ្ជូន ឧ: គេបង្គាប់មនុស្សឲ្យក្រាលនូវអាសនៈទាំងឡាយ ដើម្បី ឬ បំរុងភិក្ខុសង្ឃ, អាពុកផ្ញើទៅនូវសំលៀកបំពាក់ទាំងឡាយ ដើម្បីកូន ។

៣- "បំពោះ" ឬ "នឹង" ជាទីត្រូវគេបៀតបៀន ឧ. អ្នកណាប្រទូស្ត បំពោះ ឬ នឹងមនុស្សដែលមិនប្រទូស្ត ។

## អាយតនិបាតទី ៥– មានអត្ថ ៣ យ៉ាង:

១- "អំពី" ឬ "ចាក" ឧ. ភ័យ អំពីសេចក្តីស្នេហា, បុគ្គលគប្បីឃាត់នូវចិត្ត ចាកបាប គឺជាបុគ្គលគប្បីលះបង់បាប ។

២ – "ជាង" ជាផែនប្រៀបធៀបឲ្យដឹងថាលើស ឬ ថយ ជាដើម ឧ. សីលជាគុណជាត មានផលច្រើន ជាងទាន ។

៣– "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ជាទីមូលហេតុ-ដើមចម ឧ. សន្តិភាពនឹងក្លាយកើតព្រម ព្រោះសេចក្ដីល្អនាំគាត់ឲ្យកើត ។

## អាយតនិបាតទី ៤– មានសព្ទ ៥ ម៉ាត់ៈ

១ – "នៃ" ឬ "របស់" ជាគ្រឿងភ្ជាប់ដោយម្ចាស់

ឧ. ផ្ទះ នៃអ្នកស្រែ ឬ របស់អ្នកស្រែ ។

២ – "នៃ" ជាគ្រឿងភ្ជាប់ដោយពួក-ដោយក្រុម ឧ: ប្រជុំ នៃជនទាំងឡាយ ហ្វូង នៃគោទាំងឡាយ ។

៣ – "នៃ" ជាគ្រឿងភ្ជាប់ដោយការសម្គាល់ជាដើម ឧ. ការៈ នៃអគ្គ គឺកុសលបុគ្គលប្រើធ្វើបានដោយគម្រែ, កិច្ចដោយប្រយ័ត្នមិនបានទៀយ ព្រោះការៈ នៃតទ្ធីព្រះអភិធម្មមានគុណ កាលសម្បូរមេ ។

៤– "កាល" ឬ "កាលបើ" ឬ "កាលដែល" ជាសេចក្ដីដែលគេចូលមកប្រើហាក់ដូចជាបទប្រធានដោយឡែក ។ៈ កាលដែលទារកកំពុងយំ បិតាចេញទៅហើយ, អ្នកទាំងឡាយចូរនៅចាំក្នុងទីនុ៎ះបន្ដិចសិន, កាលបើខ្ញុំនិយាយថា: អ្នកទាំងឡាយចូរចូលមកចុះចូរមកឲ្យឆាប់ ។

៥– "ជិគុំ" ឬ "បណ្ដា" ជាសេចក្ដីដកញែកចេញឲ្យដាច់ដោយឡែកអំពីចំនួនដែលរួម ដែលប្រមូល ។. បណ្ដាមនុស្សទាំងឡាយ ក្សត្រិយ៍ក្លៀវក្លាបំផុត ។

## អាយតនិបាតទី ៣ – មានអត្ថ ៩ យ៉ាងៈ

១– "ក្នុង" ជាទីកំបាំង ។. គេអង្គុយក្នុងខាងក្នុងនៃបន្ទប់ ។

២– "ក្នុង" ជាទីដែលគ្រប ឬ លាយគ្នា ។. ប្រេងស្ថិតនៅក្នុងល្ងទាំងឡាយ, ទឹកដោះស្រស់ស្ថិតនៅក្នុងទឹក ។

៣– "ក្នុង" ជាទីអាស្រ័យ ។ ត្រីទាំងឡាយនៅក្នុងទឹក ។

៤– "ក្នុង" ជាកាល ជាពេល ៖ កុសលចិត្ត ជាចិត្តកើតឡើងហើយមានក្នុងសម័យឯណា ។

៥– "លើ" ឬ "ក្នុង" ឬ "ត្រង់" ឬ "នា" ជាទីនៃ-ទ្រ-ផ្ចាប់-ផ្ទៀតផ្ទែក ៖ ព្រះមានព្រះភាគគង់ហើយលើអាសនៈដែលគេក្រាលហើយ, ពេមទាំងឡាយបញ្ចូលខ្លួន ឬ ត្រង់ខ្លួន ។

៦– "នាកាល" ឬ "កាលបើ" ឬ "កាលដែល" ជាសេចក្ដីដែលប្រើហាក់ដូចជាបទប្រធាន ៖ នាកាលព្រះអាទិត្យអស្តង្គតហើយ ព្រះចន្ទរះឡើង, កាលបើយ៉ាងនេះមាន មានតែយើងគុះទៅ, កាលដែលមាណពនោះនិយាយច្រើនៗទៅ សរីរៈទាំងអស់នៃព្រាហ្មណ៍ ពេញល្បែកផ្សាយហើយដោយបីតិ ។

៧– "និមិត្ត" ជាគ្រឿងចំណាំ-ជាហេតុ ៖ ដីរ និគសម្លាប់ និមិត្តកុក (ព្រោះកុក-ព្រោះតែកុក) ។

៨– "ជុំនុំ" ឬ "បណ្ដា" ជាសេចក្ដីដកញែកចេញឲ្យដាច់ដោយឡែកអំពីចំនួនដែលរួមដែលប្រមូលគ្នា ៖ ជំនុំឬបណ្ដាភិក្ខុទាំងឡាយពីររូបនោះ ភិក្ខុមួយរូបដល់ហើយនូវសោតាបត្តិផល ។

៩– «ជិត» ឬ «ទៀប» ជាទីជិត-ប្រប ឧ. ស្រុកកាំងយជិតក្រុង ឬ ទៀបក្រុង, ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ។

អាលបនៈ – អាលបនៈ ជាពាក្យសម្រាប់ប្រើជាសំដីស្រែកហៅ ឬ ពោលចំពោះ មានការៈដូចស្រែកហៅ ដូចពាក្យថា: «បពិត្រ, ម្នាល, ឯ៎, ហៃ» តាមសេចក្ដីគោរព ឬ ពាក្យគោរព ឧ. បពិត្រមហារាជ សូមព្រះអង្គដ៏ចំរើនទ្រង់ឈ្នះ, ម្នាល ឬ នែកូនបូកុំទៅ ... ។

## ២៤– និបាតស័ព្ទ

និបាតជាស័ព្ទសំរាប់ជំរុំបំដីត្រង់ឃ្លាល្បះមួយៗ ជាជំនួយនាមស័ព្ទនឹងកិរិយាស័ព្ទ ឲ្យមានសេចក្ដីស្រឡះ ច្បាស់លាស់ ពិរោះស្រួលស្ដាប់ ដូចពាក្យថា: ក៏ - ក៏ដោយ - ក៏ដែរ - ដែរ - ផង - ឯ - បើ - ទោះ - ទោះបី - បើទុកជា - ទើប - ពុំនោះសោត - ពាល - ល្គឹកតែ - ព្រោះ - ស្ទើត ជាដើម ។ និបាតសំ

មានច្រើនយ៉ាងគឺ: អាយតនិបាតជាសព្ទសំរាប់ចងក្រងពាក្យ ដែលជាកម្មរបស់កិរិយា ឬ ជាពាក្យបំពេញបទរបស់នាមនាម ដូចពាក្យថា: ខ្ញុំស្តាប់ឲ្យពាក្យ, ទៅកាន់ផ្ទះ, កូនរបស់ខ្ញុំ, ភូមិផង, យើង...: ពាក្យ: ឲ្យ, កាន់, របស់, នៃ... ជាអាយតនិបាត ។ អាយតនិបាតទាំងឡាយគឺ: រំ, ឲ្យ, កាន់, អស់, ញុំាង, ចំពោះ, ដោយ, គឺ, ហេតុ, ព្រោះ, ផល់, បំរុង, អំពី, របស់, នៃ, កាលបើ, ទៀប, ដក, និមិត្ត ។ (ដូចមានពិស្តារក្នុងខាងលើ)

## និបាតប្រាប់កាល - ប្រាប់ពេល (កាលត្ថវាចកៈ)

គ្រានោះ, លំដាប់នោះ, ដងនោះ, កាលនោះ, ក្សណនោះ, ព្រឹក, អំពីព្រឹក, ថ្ងៃ, ក្នុងវេលាថ្ងៃ, ល្ងាច, វេលាល្ងាច, ម្សិល, ម្សិលមិញ, ពីម្សិលមិញ, ស្អែក, ខានស្អែក, ខានស្អែកមួយ, អម្បាញ់មិញ, ក្រាយ, រំពេច, សិន, តទៅ, ក្នុងខាងមុខ ។ល។

## និបាតប្រាប់ទី (ឋានត្ថវាចកៈ)

ខាងលើ, ខាងក្រោម, ខាងក្រោយ, ខាងក្នុង, ខាងក្រៅ, ចន្លោះ, រវាង, ស្ងាត់, ទីស្ងាត់, កំបាំង, កំបាំងពីមុខ, ចំពោះមុខ, នៅមុខ,

ដរ៉ៃ, ឯមុខ, ឯនាយ, ឯអាយ, កន្លាយ, អាយ ៗ ល ៗ

## និបាតប្រាប់សេចក្ដីប្រៀបប្រដូច (ឧបមត្ថវាចកៈ)

ដូច, ដូចជា, បីដូច, ហាក់ដូច, ប្រដូច ប្រហែលដូច, យ៉ាងណា, យ៉ាងណាមិញ, យ៉ាងនេះ, យ៉ាងនោះ, ដូច្នេះ, ដូច្នោះ, ដូចម្ដេចមិញ ៗ ល ៗ

## និបាតប្រាប់ប្រការ (បការត្ថវាចកៈ)

ម្ដេច, ដូចម្ដេច, ដោយប្រការដូចម្ដេច, ដោយប្រការនោះ ៗ ល ៗ

## និបាតប្រាប់សេចក្ដីឃាត់ហាមដាច់ខាត (បដិសេធនត្ថវាចកៈ)

កុំ, ពុំ, មិន, ឥត, ខាន, ពិត, មែន, តែប៉ុណ្ណោះ, គ្រាន់តែ, មិនមែន, មែនពិត, ទៀរលែង, ទៀរលែងតែ, លើកលែងតែ, កុំឡើយ, ណ្ហើយ, ល្មមហើយ ៗ ល ៗ

## និបាតប្រាប់សេចក្ដីតាមបានឮ (អនុស្សវនត្ថវាចកៈ)

ឮថា, បានឮថា, មានដំណាលថា ៗ ល ៗ

## និបាតប្រាប់សេចក្ដីជញ្ជឹង-ឬមើល-ល្មាត-ណាត់

(បរិកប្បត្ថវាចកៈ)

បើ, បើថា, ប្រសិនបើ, ទោះបី, ល្គីកកែ, បើដូច្នោះ, ធ្វើដូច, ម្ដេចហ្ន៎ ។ល។

## និបាតប្រាប់សេចក្ដីសួរពីណាំង (បុច្ឆនត្ថវាចកៈ)

ឬ, ឬក៏, ឬអ្វី, ឬទេ, ដូចម្ដេច, ដែរឬ, យ៉ាងដូចម្ដេច, យ៉ាងណា, ទដឹង, យ៉ាងណានេះ, នេះ, ហ៎, ហ្ន៎, ។ល។

## និបាតប្រាប់សេចក្ដីឆ្លើយ-ទទួល (សម្បដិច្ឆនត្ថវាចកៈ)

អើ, បាទ, ព្រះបាទ, ព្រះបាទម្ចាស់, ករុណា, ករុណាពិសេស, ចា៎ះ, ច៎ះ, ពរម្ចាស់, មែ, ព្រះមែម្ចាស់, ចំរើនពរ, ថ្វាយព្រះពរ ។ល។

## និបាតប្រាប់សេចក្ដីតឿន (ឧយ្យោជនត្ថវាចកៈ)

ហ៎, ដូចជាតឿន, ឆាប់ៗ ។ល។

## និបាតប្រាប់សេចក្ដីច្រើនយ៉ាង (អនេកត្ថវាចកៈ)

ក៏, ឯ, ផ្សេង, ក្ដី, ផង, មួយ, ខ្លះ, ឬ, ពិត, មែន, វិញ, អើក៏, មែនពិត, ពីព្រោះ, ក៏ដោយ, ក៏បាន, ពុំនោះ-

ហោតម្ដងមួយវិញទៀត, ចំណែកខាង. ប៉ុន្តែ, ប៉ុន្តែថា, ថ្វីបើ, ក្រែង, ដូចជា, ម្យ៉ាងទៀត ។ល។

## និបាតប្រាប់សេចក្ដីគ្រាន់តែបំពេញបទ (បទបូរណត្ថជោតកៈ)

ហ្ន៎, ហ៎, ហះ, យ៉, យ៉េ, ឯង, ទ, យ៉ោកើ ។ល។

## និបាតប្រាប់សេចក្ដីផ្សេងៗ (នានត្ថជោតកៈ)

មែន, ខុស, ទេ, ទៀត, វិញ, ខ្ពស់, តាម, ប្រាកដ, ដោយពិត, ទៅវិញទៀត, ក្រៃពេក, ក្រៃលែង, រឿយៗ, ញឹកញយ, ជាក់លាក់. ពិតឆ្ងាយ, ក៏មែនហើយ, សូម្បី, តិចតួច, ចាប់ផើម, តាំងពី, ពីដូច, កុំហាក, មួយគ្រា. មុន, តិចៗ, សន្សឹម, សំរៀម, ថ្មៗ, ញឹបៗ, មួយរយដង, មួយសន្ទុះ, ជាមួយ, ខ្លួនឯង ។ល។

## និបាតប្រាប់សេចក្ដី (ជាកាលបទៈ)

សំរាប់អ្នកគ្មានគេផះ ទៅកាន់អ្នកមានគេផះ ឬអ្នកមានគេផះ ទៅកាន់អ្នកគ្មានគេផះ ។

(ពាលបនត្តាបកៈ) សូមព្រះតេជះ, សូមព្រះតេជះ ជីគល់លើត្បូង, សូមទ្រង់មេត្តាប្រោស, សូមទានមេត្តាប្រោស, ទានប្រោស, បពិត្រព្រះអង្គ, បពិត្រព្រះករុណា, បពិត្រលោកដ៏ចំរើន, នែនាយ, នែចៅ, ព្រះវស្ដុន, រ៉ី, រ៉ីយ, នែអ្នកដ៏មានអាយុ, នែអ្នកដ៏ចំរើន, អស់លោកទាំងឡាយ ។ នាង កានាង... ។ល។

## ឧទានស័ព្ទ

ស័ព្ទសម្រាប់ប្រាប់សូរសំឡេង ឬជាសម្ដីភ្ញាក់ទាត់ដោយភ្ញាក់ផ្អើល ព្រោះមានភ័យ ឬមានសេចក្ដីត្រេកអរត្រេកពេក ។ ម៉ឹក! ប៉ុង! គ្រាំង! ប្រឹបប! ក៏ង! វ៉ែកៗ! ផ្ទុំង! ខ្ញូរខ្ញូង! ពុទ្ធោ! កម្ម! ។ល។

## បរិវារស័ព្ទ

មានពាក្យខ្លះឥតស័ព្ទប្រែ សំរាប់តែបន្ថែមសំដី ពាក្យទាំងនោះហៅថាបរិវារស័ព្ទ ។ ជាឧត្ដម បរិវារស័ព្ទភ្ជាប់នឹងនាម ឬនឹងគុណនាម មានលំនាំដូចអតិវិសេសគុណនាម ។ ពាក្យទាំងនោះគឺៈ ប្រអប់ប្រអ៊ើ, ចានក្បាន, ទូរបាំង, ស្បុក,

ចំណាំចំណុក, ត្រៃផ្សៃ, គោអំពៃ, សេះអំពែះ, មនុស្សម្នា, ចិនក្រិន, យួនព្រួន, ម៉ូះម៉ាំ, ក្មេងក្មាង, ថ្នាំសង្កូវ, ស្មៅស្រៅ, ដំណាំដំណោប, សត្វពន្ទាត់, ខំខែក, ទ្រព្យហ៍អាសាញ់, ស្គុះស្គាយ, ស្តោកស្តាំង, ក្មេងក្មាត់, ដំបងព្រនង់ ។

## ២៥ — សំខ្យា ឬ សំខ្យាស័ព្ទ

សព្ទសំរាប់រាប់ខាមហៅថាសំខ្យាស័ព្ទ ។ សំខ្យាស័ព្ទមាន ពីរយ៉ាងគឺ បកតិសំខ្យា និងបូរណសំខ្យា ។

### បកតិសំខ្យា

សំខ្យា ដែលរាប់តាមប្រក្រតីឲ្យដឹងចំនួនរបស់នាមនាមថា ប៉ុណ្ណេះ ប៉ុណ្ណោះ ដូចរាប់ថាៈ មួយ - ពីរ - បី - បួន - ប្រាំជាដើម ហៅថាបកតិសំខ្យា ។

### បូរណសំខ្យា

សំខ្យាដែលរាប់នាមនាមបន្តិបន្ទាប់ៗ តាមលំដាប់តាមថ្នាក់ ដូចពាក្យថា ដំបូង (ទីមួយ) · គំរប់ពីរ គំរប់បី · គំរប់បួន · គំរប់ប្រាំ

ជាដើមទីនិពាក្យថា: បឋមៈ - ទុតិយៈ - ចតុត្ថៈ - បញ្ចមៈ - ឆដ្ឋៈ ហៅថាបូរណសំខ្យា ។

បកតិសំខ្យាមានពីរពួកគឺ: សំខ្យាសព្ទនាម ១, សំខ្យាគុណនាម ១ ។ សំខ្យាសព្ទនាមមានដូចគឺ: មួយ - ពីរ - បី - បួន ។

សំខ្យាសព្ទទាំងពីរប្រាំកម្រិតសិនជាគុណនាមទាំងអស់ ។ ឯបូរណសំខ្យាជាគុណនាមទាំងអស់ដែរ ។

វិធីប្រើសំខ្យាសព្ទ — នឹងរាប់វត្ថុ ។ គេដាក់សំខ្យាហៀងភ្ជាប់ពីក្រោយនាមនាម ឬភ្ជាប់ខាងមុខនាមនាម តាមដោយទំនងស្រួលជាគន្លងភាសា ។ ដូចរាប់ថា ១ រៀល - ពីររៀល - មួយពាន់ម៉ែត្រ - មួយសែនហាប - មួយលានតោន... គោពីរ - សេះហុកសិប - ឥដ្ឋមួយម៉ឺន - ពាហានមួយកោដិ - ស្វាយប្រាំស្លឹក ... ក្នុងជម្រង - ថ្នាក់បន្ទាប់ - សេចក្តីគំរប់ប្រាំពីរ - បឋមដ្ឋាន - បឋមសាល - ទុតិយវិជ្ជា - បញ្ចមី - ឧបោសថ ។ល។

## ២៦ -- បុព្វបទ

អ (សំរាប់បដិសេធ) ស័ព្ទ "អ" ជាបុព្វបទសំរាប់បដិសេធ ។ "អ" បដិសេធនេះសំរាប់រៀងភ្ជាប់ទីដើមស័ព្ទផ្សេង សេចក្ដីខាងន័យថា: កុំ - មិន - ឥត - ពុំមែន ដូចពាក្យ: អកតញ្ញូ - អភ័ព្វ - អកុសល - អភ័យ - អទុក្ខ - អរោគ - អនត្តា - អធម្ម - អគតិ - អគោចរ... ជាដើម ។ "អ" បដិសេធនេះប្រើជាបុព្វបទហៅថា "អ" បុព្វបទ ។ មានបុព្វបទពួកមួយទៀត សំរាប់រៀងភ្ជាប់ខាងដើមពាក្យ ។ បុព្វបទទាំងនោះខាងន័យថា ឲ្យ... ធ្វើឲ្យ... ដូចពាក្យថា: កកាយ - បញ្ចូល - បណ្ដាញ - បង្អិល - បន្ទូរ - បណ្ដុយ - បង្រួម - បណ្ដើរ - ទាស់ទែង - បង្វែរ - បំពាល - បញ្ច្រាស់ - បង្រៀន... ជាដើម សុទ្ធជាពាក្យផ្សំអោយបុព្វបទ ក បញ្ញ បណ្ណ បន ញ ទ បំបង... ។

## ២៧ — អាគម

គេហៅថាអាគមគឺអក្សរចុះថែមត្រង់ចន្លោះផ្គួបពាក្យថា: ចតុរង្គ-និរន្តរ-បរិយោសាន-ចតុរារិយសច្ច... ។ ចតុ-អង្គ ជាចតុរ-អង្គ ជាចតុរង្គ, និ-អន្តរ ជានិរ-អន្តរ ជានិរន្តរ, បរិ-ឱសាន ជាបរិយ-ឱសាន ជាបរិយោសាន, ចតុ-អរិយសច្ច ជាចតុរ-អរិយសច្ច ជាចតុរារិយសច្ច, អក្សរ រ-យ ដែលយកមកថែមដើម្បីសំរួលស័ព្ទអាន ហៅថា អាគម ។ អាគម សំរាប់ប្រើតែក្នុងភាសាបាលី និងភាសាសំស្រ្កឹត នោះអក្សរដែលយកមកប្រើជាអាគមមានចំនួនសំរេច ។

## ២៨ — ឧបសគ្គៈ

ឧបសគ្គ ជានិបាត គឺជាពាក្យមួយសព្ទ (ពាក្យមិនផ្លាស់ប្តូររូបនឹងសព្ទ) ដូចជានិបាតនានាដែរ តែពួកនិបាតដែលហៅថា

ឧបសគ្គៈនោះ មានចំនួនតែ ២០ ស័ព្ទៈ ហើយមានរបៀបបែបផែនក្នុងវិធីបង្កើតពាក្យដោយខ្សែកំណើតពីធាតុនានា ៗ ក្នុងការបង្កើតភ្ជាប់ពាក្យ គេដាក់ឧបសគ្គៈជាខាងដើមនាមស័ព្ទ និងកិរិយាស័ព្ទ ៗ

ឧបសគ្គៈទាំង ២០ ស័ព្ទគឺៈ

អតិ ប្រែថា កន្លង - ក្រៃ - ក្រៃពេក - ពេក ...

អធិ – ក្រៃលែង - ក្រៃពេក - លើសលុប - លើសលែង - សង្កត់

អនុ – តាម - តូច - បន្ទាប់ - រង - ក្រោយ - បណ្ដោយ - លំដាប់

អប – ប្រាស - គេច - វៀស ...

អបិ ឬ បិ – ជិត - ខាងលើ ...

អភិ – ក្រៃពេក - ធំ - ចំពោះ - ឆ្ពោះ - ខាងមុខ ...

អវ ឬ ឱ – ចុះ - ចុះក្រោម - ទាប - ស្រេច ...

អា – ទូទៅ - សព្វ - ក្រៃលែង ...

ឧ – ឡើង - ខ្ពស់ - ក្រៅ ...

ឧប – ជិត - ចូលទៅជិត - មាំ - ស៊ប់ ...

ទុ – អាក្រក់ - ក្រ - កម្រ - លំបាក ...

ប្រែថា ចេញ-មិនសល់-មិនមាន-អត់...

និ — ចេញ-ចូល-ចុះ...

ប — ចូលទៅ-ខាងមុខ-ចេញ មុខ...

បដិ-បតិ — បំពោះ-តប-ត-ប្រាស-ត្រឡប់...

បក — ខាងមុខ...

បរិ — ជុំ-ជុំវិញ-គ្រប់គ្រាន់-ស្រេច..

វិ — ផ្សេង-បែក-ច្បាស់-ជាក់- ប្លែក...

សំ — ព្រម-ជាមួយ-ល្អ-ប្រពៃ...

សុ — ងាយ-ស្រួល-ស្រណុក-ល្អ-ប្រពៃ-ណាស់-ម៉េះ...

ពាក្យដូចមានតទៅសឹងជាពាក្យមានឧបសគ្គៈ

បរិបូណ៌ ទុរគត(ទុគ្គត)បរាជ័យ-អនុគ្រោះ-អភិបាល-អធិការ-អវសាន-(បរិ-ឱសាន)បរិយោសាន - ឧបការ - និរភ័យ -អធិបតី-វិកាល -វិបរិត-សុភិក្ខា -ទុភិក្ខា -អបរាជ័យ-និរន្តរ-និរទោស-អធិជ័យ-អនុនាយក- អនុស្សាវរា- សុគតិ-សុគន្ធ -វិជ័យ -ទុក្ខិត... ។

# ២៩— សម្ពន្ធ

សម្ពន្ធគឺការរៀបចំបទ ក្នុងប្រយោគ ។ ដើម្បីភ្ជាប់ពាក្យទាំងឡាយក្នុងសង្កាត់មួយៗ ឬក្នុងប្រយោគមួយ ត្រូវឲ្យដឹងថាបទណា ត្រូវទៅនឹងបទណា តាមលំនាំវេយ្យាករណ៍ ។

ឧទាហរណ៍: ១ — "ឈ្មួញ ដឹក ស្រូវ"

ឈ្មួញ : នាម, សាធារណៈ, ឯកវចនៈ, បឋមបុរិសៈជាប្រធានរបស់កិរិយា ដឹក ។

ដឹក : សកម្មកិរិយា, បច្ចុប្បន្នកាល, ឯក. ។

ស្រូវ : នាម, សាធារណៈ កម្មនៃអំពើ ដឹក ។

២ — "ស្ដ្រីៗ ទូល បន្លែ ដោយ កញ្ជើ"



ស្ដ្រីៗ, នាម, សាធា. ពហុ. បឋមបុរិសៈ ជាប្រធានរបស់កិរិយា ទូល ។

ទូល : សកម្មកិរិយា, បច្ចុប្បន្នកាល, ពហុ ។

បន្ទូល : នាម, សាធា. ពហុ. កម្មរងអំពើកិរិយា ទូល ។

ដោយ : អាយតនិបាត

តញ្ញើ : នាម, សាធា. ឯក. អកម្មរងអំពើ ទូល ។

" បងខ្ញុំ សង់ ផ្ទះថ្មីមួយ នៅផ្លូវនរោត្តម "

បងខ្ញុំ : បទមេផ្សំលុប (កាត់បទពីបងរបស់ខ្ញុំ ឬបងនៃខ្ញុំ),

នាម, សាធា. ឯក. បឋមបុរិសៈ ជាប្រធានកិរិយា សង់ ។

សង់ : សកម្មកិរិយា, បច្ចុប្បន្នកាល, ឯក. ។

ផ្ទះ : នាម, សាធា. ឯក: កម្មរងអំពើ សង់ ។

ថ្មី : បកតិគុណនាម, ឯក. គុណបទរបស់ផ្ទះ ។

មួយ : សំខ្យាគុណនាម, ឯក. គុណបទរបស់ផ្ទះ ។

នៅ : និបាតភ្ជាប់វ័ ។

ផ្លូវនរោត្តម នាម: អសាធា. ឯក. អកម្មរងអំពើ សង់ ។

## ៤ – "ឯង កុំដើរលេង ឡើយ"

ឯង: មជ្ឈិមបុរិសៈ (ម. បុ. សព្វ) ប្រធាន ដើរលេង: ឯក. ។

ដើរលេង: អកម្មកិរិយា, ឯក. បច្ចុប្បន្នកាល ។

កុំឡើយ: និបាត បដិសេធ (បដិសេធនត្ថវាចកៈ)

## វិធីហាត់

១ – ចូរដាក់លិង្គនៅខាងមុខនាមនាមនិមួយៗ ៗ ឲ្យមានដូច ប្រុស (បុំលិង្គ) ស្រី (ឥត្ថីលិង្គ)

| | | |
|---|---|---|
| ប្រុស... | យក្ខ, យក្ស... | វាទី .. |
| ស្រី... | យក្សា... | វាទិនី ... |
| ឪពុក... | យក្ខិនី... | ទេវី... |
| ម្ដាយ... | យក្សិណី... | ម្រាក់... |
| ម៉ា... | ទេវបុត្ត... | តាបី ... |
| ម៉ី... | ទេវធីតា... | តាបិនី ... |

| | | |
|---|---|---|
| តា... | នាងមេខលា... | តារី... |
| យាយ... | កិន្នរ... | ពានរ... |
| កុមារ... | កិន្នក... | ពានរី... |
| កុមាក... | កិន្នរី... | ទាយក... |
| កុមារី... | បក្ខ, បក្សា... | ទាយិកា... |
| ភិក្ខុ... | បក្សី... | ឧបាសក... |
| ភិក្ខុនី... | ព្រាហ្មណ៍... | ឧបាសិកា... |
| សាមណេរ... | ព្រាហ្មណី... | សិក្ខមានា... |
| សាមណេក... | តោក... | ទាសី... |
| សាមណេរី... | តោរី... | ទាសា... |

២_ ចូរដាក់វចនៈ ត្រង់ពាក្យនាមនាមនិមួយៗ ឲ្យមាដូចមនុស្សទាំងឡាយ (ពហុវចនៈ ឬពហុ.) របស់, (ឯកវចនៈ ឬឯក.)

| | |
|---|---|
| មនុស្សទាំងឡាយ... | សិស្សានុសិស្ស... |
| ឈើ... | ក្រស្តប្រជា... |

| | |
|---|---|
| គ្រូ ... | ជនានុជន ... |
| ថ្ងៃទាំងឡាយ ... | ហានាឧក្រម ... |
| ភជាទាំងឡាយ ... | របស់ទាំងឡាយ ... |
| សេះព្រី ... | ពស្ត្រា ... |
| ដំរីបី ... | ផ្ទះទាំងឡាយ ... |
| រទេះទាំងឡាយ ... | ព្រាហ្មណ៍ ... |
| ចូស៊ៀ ... | ភោជនាហារ ... |
| កុមារ ... | ទោសានុទោស ... |

## ៣ - បទគុណនាម

| | | | |
|---|---|---|---|
| ល្អ | ប្រសប់ | ខ្ពស់ | រាវ |
| ចាំ | ស្រួយ | ទាប | ខាប់ |
| ជាប់ | ធុយ | ស្អិត | ក្រអូប |
| ស្គម | រឹង | គំរក់ | ស្អុយ |
| ថ្លៃ | ទន់ | ក្តី | ស្រួច |

| | | | |
|---|---|---|---|
| ធាត់ | ធំ | ស្រគាប់ | ចាស |
| ស | តូច | ខ្ចី | ក្រិន |
| ខ្មៅ | ស្តើង | វែង | វៀច |

៤- ចូរភ្ជាប់គុណនាមដូចមានខាងលើ **នឹងនាមនាមមួយៗ**
**តាម**សមគួរ ៗ ឧបមាដូចៈ ធ្មេញវែង-ក្មេងតំរក់-ចុងកាំបិត... **។**

| | | |
|---|---|---|
| ធ្មេញ... | ក្ដំ... | បន្ទាត់... |
| ក្មេង... | ពស់... | ផ្លូវ... |
| របង... | ស្លឹក... | មួក... |
| ឈើ... | មេឃ... | ឆ្កែ... |
| ថ្ងៃ... | កន្ទេង... | ទឹក... |
| មេទាហាន... | កង... | ក្ដារ... |
| ក្រដាស... | មនុស្ស... | ដែក... |
| ស្បៀង... | ភ្លើង... | ជាងចង... |
| ផាន... | កញ្ចក់... | កែវ... |

ដស ... បន្ទុលដៃ ... ព្រះអាទិត្យ ...

ឥដ្ឋ ... វត្ត ... បាន ...

ថ្ម ... ផ្កា ... ក្រមួន ...

ញូក ... កន្ទួល ... ដំបៅ ...

៤– អតិវិសេសគុណនាម

ខ្មៅណាស់ លឿនក្អូត ស្រួយខ្លាក តឹងម៉ឹង

ម៉ដ្ឋសុង ខ្ពស់ត្រដែត ធំធេង វែងនក្តូន

ក្តៅរលាន ខ្ចីក្រឡុញ សក្បុស ពងធេង

ថ្លាយង់ ឆើតឆាយ ខៀវស្រងាត់ ស្ងួតហៀវ

រហ័សប្រិល ឆ្ងាយសន្ធឹម ផុយរេម មូលក្រឡង់

៥ – ចូរនាមនាមទាំងនេះ ចុះដាក់លក្ខណៈនាម**គួរសម** នឹងអតិវិសេសគុណនាមខាងលើនោះឯង ។ ឧទាហរណ៍ៈ **សក់ ខ្មៅរលើប** ... ។

សក់មានពណ៌ ... ។ ពិលផ្កាយណ៍ផាពិល ... ។

| | |
|---|---|
| ក្មេងនេះមានសាច់... | បានជាវិគ្រ... |
| ខ្ញុំមានតុ... | មើលទៅឃើញភូមិ... |
| ទឹកនេះ... | ភ្នំនោះមានពណ៌... |
| មនុស្សនេះ... | សម្ព្យាះជាសរសៃ... |
| ព្រាបហោះ... | គេបង់ចំណាន... |
| ខ្ទួងទៀន... | ដែកនេះប្រែករ... |
| ម្រាមដៃក្មេង... | ភូមិនេះសង់លើដី... |
| កងរបស់កុមារនេះ... | ជញ្ជាំងផ្ទះនេះធ្វើនឹងក្ដារ... |
| ព្រៃនោះ... | ព្រះអាទិត្យមានរង់... |

## ៧ – វិសេសគុណនាម

| | | | |
|---|---|---|---|
| ចេះជាង | ប្រសប់ជាង | ជាប់ជាង | ខ្លៅលើស |
| យឺតជាង | រហ័សជាង | ផុយជាង | សប្លែក |
| ល្អប្លែក | ខ្ពស់លើស | រឹងជាង | ល្អិតជាង |
| ថ្លាជាង | ធាត់ប្លែក | ទន់ជាង | ទាបជាង |

៨– ចូរដាក់លក្ខណៈនាមបន្ថែម នឹងពាក្យនិមួយៗ ដោយវិសេសគុណនាមខាងលើ ។ ឧទាហរណ៍: ក្មេងនេះប្រសប់ជាង, កូនបិស្សនោះឆ្លាតជាង ... ។

ក្មេងទាំងឡាយ ក្មេងនេះ... ។ ឈើដាប់នោះផ្លែកជាឈើ ... ។ យានទាំងឡាយ រទេះគោ ... ។ ត្បូងពេជ្រត្រ... ត្បូងទាំងអស់ ។ កុំនៅស្រុកខ្មែរ-កុំបុកគោ ... ។ គ្មានរបស់អ្វី... ជាងថ្ម ។ ទឹកម៉ាស៊ីន... ទឹកស្រះ ។ ដែលជាលោហធាតុ... ធាតុឯទៀត ។ ស្បែកមនុស្សទាំងពួង ស្បែកបាកាំង... ។ គ្មានអ្វី ... លើស ប្រែក្សណ៍ខ្មែរ ។ ធម្មជាតិល្អិត គ្មានអ្វី ... អាកាស ។ វត្ថុទន់ នោះសំឡីជាសរសៃ ... ។

៩– នូវកិរិយាទាំងឡាយ ចូរបំបែកជាកិតនាម ឬ នាមក្រិត ។ ឧបមាដូចពាក្យៈគិត ជាគំនិត, ខ្ទប់ ជាបន្ទប់... ។

គិត ... កាត់ ... សិត ... គូស ...

ចង ... កោស ... ស្ងួន ... កាន់ ...

ឃាន ... ដឹង ... ជួញ ... ចិក ...

ដោរ ...  ទើរ ...  ទិញ ...  គេណ្ហ ...

ដើរ ...  ខ្ជួញ ...  ចត ...  សៀក ...

ដេក ...  ឫស ...  ប៉ះ ...  កោរ ...

ដាំ ...  ឫស្សី ...  កាត់ ...  គាល់ ...

ទំ ...  ពូន ...  រៀប ...  សួរ ...

១០ – ចូររកនាមក្រិតចេញពីគុណនាមមួយ ៗ នេះ ៗ

ឧបមាដូច: ធ្ងន់  ជាទម្ងន់ ... ៗ

ធ្ងន់ ...  ខ្វាក់ ...  ចាំ ...  ធំ ...

ទាប ...  ខ្វិន ...  ស្អុយ ...  ក្រាស់ ...

ខ្ពប់ ...  ឈឺ ...  ឆ្ងាយ ...  ខ្ជិល ...

ស្រាល ...  ចេះ ...  ផ្អែម ...  ឆ្ងាញ់ ...

រឹង ...  ថ្លៃ ...  ក្ដី ...  ខ្សត់ ...

លួច ...  ស្ដើង ...  ចាស់ ...  តាស់ ...

ណោក ...  កាច ...  ល្អ ...  ខូច ...

## ៦៨– ថ្នាក់ មធ្យមជាន់ និង ឧត្តមជាន់

១១– ចូរកើតកិរិយាក្រិតចេញពីពាក្យមួយៗខាងក្រោមនេះ ។

ដូចពាក្យ : ត្រង់ ជា ដំរង់ ឬ តម្រង់ ... ។

ត្រង់ ... ដំនៀល ... ចំងាយ ... ទ្រនាប់ ...

ត្រូវ ... ចំណេញ... បំណាស់... ចំណាប់...

ដំណោះ... ចំណោទ... បំណុល... ស្អាត...

ដើរ... ចំណាយ... អំនួត... ផ្គត់...

ចំនើប... ប្រែង... ទ្រទិ... ក្អែន...

១២– ចូរភ្ជាប់បុព្វបទ “ ក-ប-ប្រ-បង់-បញ-បណ-បន-បំ-ទ-ញ” នឹងពាក្យកិរិយានីមួយៗ តាមដោយសមគួរ ។

ដូច: កាយ ជា កកាយ, ការ ជា បង្ការ ។

កាយ ... ដួន ... រួម ... ដុល ...

ការ ... ដោរ ... ថែម ... មើល ...

ខាត ... ឈ្លោះ ... ករ ... ខាំ ...

គរ ... ឈឺ ... ខាន ... ខំ...

គាប់... ដេញ... លាក់... ចាញ...

ចូល... ដើរ... ក្អួច... រួញ...

ចេញ... ដំ... ថៃ... តប់...

ធុក... រៀន... ចិត... ញឹម...

១៣— ចូររកបុព្វបទដែលមានន័យថា: "ក្រៀវ" មកភ្ជាប់នឹងពាក្យនីមួយៗ នេះឧបមាដូចពាក្យ: "ទំ ផា បន្ទុំ" ។

ទំ... រត់... រៀប... ទាំ...

កាប់... ផល់... ពែក... ខូច...

ស្ទាប់... ដឹង...... ហាត់... រួម...

កើត... ខាន... រលំ... រឹត...

រៀន... ឡើង... យល់... ផ្សំ...

ឈើ... បុះ... តាប់... ផុះ...

ដេក... ក្អឹ... សិក្ខ... ផ្កាច់...

ឈរ... ទុំ... ចាល់... ប្តឹង...

១៤— ចូររកគុណនាមដោយគួរតាមភាព មកបំពេញបទនៃពាក្យទាំងនេះៗ ឧបមាដូចពាក្យថា: "ពស់មានពិសខ្លាំងក្លាច" ។



ពស់មានពិសជាសត្វ ... ។ មនុស្ស ... គឺមនុស្សដែល មានខ្លួនអវយវៈ ។ ខ្លាជាម្រឹគ ... ។ គគីរជាឈើ ... ហើយ ... ណាស់ ។ ក្ដាំខ្នាលជាបពិត .... ។ ច្នុជាធាតុមួយ .... ។ មនុស្សឈឺមានកាយ ... ។ ផ្លែឈើទុំញ្ញាសមានក្លិន ... ។ អ្នកទុគ៌តជាមនុស្ស ... ។ ព្រះចន្ទពេញបូណ៌មីមានរស្មី ... ។ ទឹកសមុទ្រមានរសជាតិ ... ។ ភ្លើងជាធាតុ ... ។ ដែកជា លោហធាតុ ... ។ មេឃ ... គឺមេឃដែលគ្មានពពក ។ លោ- ហធាតុ ... គឺសំណ ... ។ ខ្យល់ពីងផើងជាខ្យល់ ... ។ ពេជ្រ ជាត្បូង ... ហើយ ... បំផុត ។ ស្នោជាវត្ថុជាតិមួយ ... បំផុត ។ មនុស្សធ្វើការបានអីយជាមនុស្ស ។ ព្រះអាទិត្យមានរស្មី ... ។

១៩ – ចូររកពាក្យ មកភ្ជាប់ទីប្រធាន :

ឧទាហរណ៍: ព្រះអាទិត្យ បំភ្លឺ លោក... ។

ព្រះអាទិត្យ... លោក ។ ដាំដែក... លោហធាតុ នឹងស្ពាន់ ។ ព្រះចន្ទ្រ... យប់ ។ ដាំដុះយក... ផ្លែឈើកំពែងកាំង ។ ព្រះធរណី... មនុស្សនឹងសត្វ, គ្រឿងក្រាន នៅក្នុងបំណុំព្រះកម ។ គ្រូ... សិស្ស ។ ពស់... រុំករវក់ ។ ច្បាប់... ឲ្យយើង ប្រតិបត្តិតាម ។ អណ្ដើក... ក្នុងទឹកនឹងលើគោក ។



យើង... ប្រណិប័តន៍ អាពុកម្ដាយ ។ អ្នកនេសាទ-ត្រី... សំណាញ់ ។ ដាំ ចង... មាសក្ដើប្រអប់ ។ ព្រានព្រៃ... សត្វទឹងស្លា ។

# ៣២ - ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន





១៦ - ចូររកប្រធានតាមសេចក្ដីភ្ជាប់នឹងកិរិយានីមួយៗនេះ ៗ

ឧទាហរណ៍ ៖ ចោរ លួចទ្រព្យគេ ... ៗ

... លួចទ្រព្យគេ ៗ ... កៀរត្រីនឹងព្រួល ៗ

... រៀនអក្សររៀនលេខ ៗ ... បររទេះនឹមគោ ៗ

... លេបកន្ទួប ៗ ... ជាផលជាតិ ៗ ... សិក្សាធម៌ ៗ

... រស់នៅក្នុងទឹក ៗ ... ដេញទន្សាយ ៗ ... ចំឡង

ពាក្យដែលគ្រូបង្គាប់ ៗ ... លប់សំពត់ក្នុងសាលាតាង ៗ

... ពន្យល់ពាក្យនៅការរៀន ៗ ... ធ្វើតាមចំពោះសង្ឃ ៗ

... ដាំដែកមិនញញើត ៗ ... គយល្វទឹកត្រី ៗ ... អុំទូក

ទឹកប្រៅ ៗ

១៧– ចូររកពាក្យផ្ទុយនឹងពាក្យទាំងនេះ :

ឧទាហរណ៍: មនុស្សឆ្គត់ឆ្គង: មនុស្សស្វះស្វាយ ...។ មនុស្សឆ្គត់ឆ្គង...។ ផ្លូវគ្រើមហើយវែង...។ ក្មេងខ្សោយ...។ សេះធាត់...។ កូនសិស្សខ្ជាប់ខ្ជួន... ។ ឈើស្ងួត... ។ ជាងប្រសប់... ។ ដែករឹង... សំណ...។ មនុស្សអ្នកមាន...។ សាច់ស្អុយ...។ ផ្កាចម្ប...។ មនុស្សពាល...។ មាសលឿងទុំ... ក្រោក...។ ឆ្កែកាច...។ យប់ងងឹត... ថ្ងៃ...។ ផ្លែឈើទុំ...។ គ្របីបាញ់ក្តៅ... គោចាញ់...។ ស្បែកគគ្រាត...។ សេះលឿន... គោ...។ កាំបិតមុត... ។ ខ្លាធំហើយហាវ... ឆ្មា... ហើយ...។

១៨ – ចូររកពាក្យមកបំពេញកន្លែងចន្លោះ

ជនណាប្រតិបត្តិតាមច្បាប់នឹងបានសុខ, ជនណា... ច្បាប់នឹងមានទោស ។ ក្នុងសម័យដែលស្រុកសុខ, ការតាំងតូងបានចំរើន ។ ក្នុងសម័យដែលស្រុកមាន..., ការតាំងតូងនឹងអន្តរាយ ។

មនុស្សណាដែលគិតតែសុខ, អ្នកនោះនឹងបាន... ។ នរណាយកគុណមកជាទីតាំង, អ្នកនោះនឹងបាន ... ។ ជនណាឃើញខ្លួនឯងថាជាមនុស្សក្រ, ជននោះនឹងជាអ្នក ... ។ ជនណាឃើញខ្លួនឯងថាជាអ្នកប្រាជ្ញ, ជននោះជាបុគ្គល ... ។ នរណាតាំងខ្លួនជាខ្លៅ, នរណានោះជាអ្នក ... ។

១៩ – ចូររើសរកពាក្យដែលមានន័យប្រហែលគ្នា (វេវចនៈ) នឹងពាក្យដូចមានតទៅ ៖

ឧបមាដូច: ចរ គឺត្រាច់ - ទៅ - យាង - និមន្ត ...

| | | | |
|---|---|---|---|
| ចរ... | យំ... | សំដៅ ... | បញ្ជូន ... |
| ដេក ... | ចិញ... | បិទ ... | ប្ដឹង... |
| ស៊ី... | ឲ្យ... | ដក... | ប្រដៅ... |
| មើល... | លេង... | លុប... | កាត់... |
| គិត... | ឈឺ... | បំពេញ... | បំភ្លឺ... |

# ៣០ - សមាសនាម

នាមនាមមានច្រើនយ៉ាង ។ នាមដែលគេតាំងឡើងឯង ១ ហៅជាបកតិនាមដូចពាក្យៈ ផ្ទះ - សេះ - ដី... ។ នាមដែលបែកចេញពីកិរិយាឬគុណនាមហៅជានាមក្រិត ឬកិតនាម ដូចពាក្យៈ ដំណើរ-ចម្ងន់ ( មកពីដើរ - ពីធ្ងន់ ) ។

នាមដែលភ្ជាប់គ្នាពីរពាក្យ ឬច្រើនពាក្យជានាមមួយ ហៅជាសមាសនាម ។ សមាសនាមជានាមភ្ជាប់គ្នាដោយនាមនឹងនាមក៏មាន, ដោយនាមនឹងគុណនាមក៏មាន ដោយនាមនឹងកិរិយាក៏មាន, ដោយកិរិយានឹងកិរិយាក៏មាន; សមាសនាមមានពីរយ៉ាងគឺ: នាម-សមាសបាលី ១, នាមសមាសខ្មែរ ១ ។ នូវនាមសមាសបាលី បើកាលណាពាក្យដែលបកមកភ្ជាប់ ជាពាក្យកើតឡើងអំពីស្រះពេញត្រូវផ្លាស់ស្រះនោះជាស្រះនិស្ស័យ ឧបមាដូចពាក្យៈ "គជ-ឥន្ទ្រ ជាគជេន្ទ្រ" "ជន - អធិបតី ជាជនាធិបតី" ។ សមាស-នាមពាក្យខ្មែរគឺ: ជង្គង់ទាន - ពស់វែក - ក្រដាសប៉ុយ - ជើងមា -

គ្រប់ស្រួល - គោរសៀម - ថ្នាំកូឡា - ផណ្ដើរ - ផលានុផល - សិក្សាធិការ - លោកុត្តរ - សាសនោបាយ - ទៀត ... ។

## វិធីហាត់

ចូរសរសេរតម្រៀបពាក្យតាមដូចមានខាងក្រោម :

សិស្ស + អនុសិស្ស = សិស្សានុសិស្ស ។ លោក + ឧត្តរ = ... ។ ផល + អនុផល = ... ។ លោក + ឥស្សរៈ = ... ។ គុណ + អានិសង្ស = ... ។ ពរ + ឥន្ទ្រ = ... ។ ផល + អាហារ = ... ។ សាសនៈ + ឧបាយ = ... ។ សត្វ + អធិដ្ឋាន = ... ។ ពុទ្ធ + អនុញ្ញាត = ... ។ គុណ + ឧត្តម = ... ។ ផល + អធិបតី = ... ។ ឧបត្ថម្ភ + អាចារ្យ = ... ។ នរ + ឧត្តម = ... ។ ផល + អនុគ្រោះ = ... ។ គាថា ... ផ្ទះវ៉ូរ ... ដើមអាំ ... ណាវៃ ... រនេះគេ ... ។

គេនិយាយនេះប្រើកិរិយា បំពេញនិងគុណសព្ទជាខាងផ្សេងៗ ដូចពាក្យថា: អ្នករក - អ្នកចូល - អ្នកដើរ - អ្នកទៅ - អ្នកមក ... សព្ទជាកិរិយាប្រើជាខាង, អ្នកធំ - អ្នកតូច - អ្នកខ្ជិល - អ្នកប្រសប់ -

អ្នកប្រាជ្ញ-អ្នកខ្លៅ... សំនឹងជាគុណនាមប្រើជានាម, នាមទាំងឡាយនេះហៅថាការកនាម ។

ចូរចុះសំគាល់ថាពាក្យ: បកតិ, កិត, សមាស, ការកៈ នៅមុខនាមនិមួយៗ :

ឈើគូស (សមាស) ដំណែង... គោខ្វារ... កាំភ្លើងដៃ...

ផ្លូវ... (បកតិ) ចារ៍... អ្នកស្រែ... សិក្សាធិការ...

ដំណើរ... ប្រើរង... ម្តាយមីង...



គុណបុត្ត... ដែក... អ្នកប្រាជ្ញ...

ផ្ទុកធំ... គជេន្ទ្រ... អ្នកចាំ...

ដំហាន... ម្ដាយធំ... ឥន្ទ្រាធិរាជ...

ស្រូវស្រែ... ទឹកឃ្មុំ... រថភ្លើង... មហាសថ...

អ្នកខ្វិល... ផ្ទះផ្សារ... បន្ទាត់... ចតុរង្គ...

មនុស្ស... ទំនិញ... ដៃខ្មៅ... នាគរាជ...

សត្រូ...: ចានស្រប... កាំបិតកោរ... ពានរ...

តិរ្ដក... សេះទឹម... ធូស្សស្រុក... យក្សណី... ។

ពាក្យប្ដូររូបព្រោះផ្លាស់អក្សរសើដ៏ជាពាក្យកើតពីព្យញ្ជនៈ វ ។

ឧបមាដូចពាក្យៈ ពិលា = វិលា, ពិសាខ = វិសាខ ។

ចូរផ្លាស់តួ វ ជាតួ ព ឲ្យពាក្យដូចមានតទៅ៖

វេលា... វេយ្យាករណ៍... វន... វេរី...

វាក្យ... វ្យាធិ... វោមរក្ខ... វេវតា... វរត្ថា...

វ្យាបាល... វុត្តិ... វេស្យា... វរ = ព្រះ... វារ...

វៀរ... វ្ឫក្ស... វ្យញ្ជនៈ... វយុ... ប្រថវី...

វ្ឫហស្បតិ... ។

សេចក្ដីចំណាំ – ពាក្យដែលផ្លាស់ វ ជា ព ច្រើនតែពាក្យបាលី នឹងពាក្យសំស្ក្រឹត ដែលប្រើក្នុងភាសាខ្មែរ ។

## ៣១ – ពាក្យកើតពីអក្សរ ប្ឋ ថ ស្ឋ ស្ត ស្ក

ពាក្យជាច្រើនកើតពីអក្សរ ប្ឋ ថ ស្ឋ ស្ត ស្ក ។ អក្សរ ប្ឋ សម្រាប់តែពាក្យដែលជាបាលី ។ អក្សរ ស្ឋ ស្ត ស្ក សម្រាប់

តែពាក្យជាសំស្រ្កឹត ៗ អក្សរ ឋ ប្រើជាពាក្យក្លាយបាលីឬសំស្រ្កឹត ឬជាពាក្យខ្មែរសុទ្ធ ដូចពាក្យៈ បឋម-ឋាន ... ជាបាលី ៗ ប្រថម-ស្ថាន...ជាសំស្រ្កឹត ៗ បឋម-ឋាន ... ក្លាយ ៗ ថន ...បាលី ៗ ស្តន ... សំស្រ្កឹត ៗ ជេដ្ឋ ... បាលី ៗ ជេស្ឋ ... សំស្រ្កឹត ៗ

## វិធីហាត់

ចូរផ្លាស់តួអក្សរ ឋដ្ឋ ជា ថ-ស្ថ-ស្ត-ស្ឋ តាមដោយភាពរបស់ពាក្យ ៗ ឧបមាដូចពាក្យៈ បឋវី ផ្លាស់ជាប្រថវី ៗ

បឋវី... ឋន... ឋលបឋ ... ថូប ...

ហត្ថ... ឋាវរ ... ឋលយាន ... សាវត្ថី ...

ឧដ្ឋ ... អធិដ្ឋាន ... ឋានានុក្រម ... ថនិកសត្វ ...

ជេដ្ឋ ... មតិដ្ឋាន ... ឋិត ... ឋី (ភេទផ្ទុយនឹងប្រុស)

ឋិតថេរ ... វត្ថុ ... រដ្ឋ ... ឋាមិយ ..

ឋាន ... ឧយដ្ឋាន ... ឋ្ត ... គោឃាតដ្ឋាន ...

# ៣៦ - ព្យញ្ជនៈផ្លាស់រូប

## តែសព្ទគង់នៅដដែល

ពួកពាក្យខ្លះទៀតផ្លាស់រូប តែស័ព្ទរបស់ពាក្យនៅដដែល ដូចពាក្យៈ អក្ខរៈ ផ្លាស់ជាអក្សរ, ខត្ត ផ្លាស់ ជា ក្សេត្រ, ខ័យ ជាក្ស័យ, ចក្ក ជាចក្រ, បុត្ត ជាបុត្រ, បញ្ញា ជាប្រាជ្ញា, កទ្ធុបទ ជាកទ្របទ, បុញ្ញ ជាបុណ្យ, កិច្ច ជាក្រិត្យ, បច្ឆិម ជាបស្ចិម, អច្ឆរិយ ជាអស្ចារ្យ, វិជ្ជា ជាវិទ្យា, មជ្ឈិម ជាមធ្យម, ឈាន ជាធ្យាន, ពជ្ឈ ជាពេធ្យ ... ។

ព្យញ្ជនៈផ្លាស់ក្នុងដូចមានខាងលើគឺ: ១ - ក្ខ ផ្លាស់ជាក្ស, ត្ត - ទ្ធ - ក្ក ផ្លាស់ ជា ត្រ - ទ្រ - ក្រ, ច្ច ជា ត្យ, ជ្ជ ជា ទ្យ, ច្ឆ ជា ស្ច, ញ្ញ ជា ណ្យ - ន្យ, ញ្ញ ជា ជ្ញ, ឈ ជា ធ្យ ។

## វិធីហាត់

ចូរផ្លាស់ក្នុងព្យញ្ជនៈនៃពាក្យ បើក្នុងនោះគួរគប្បីផ្លាស់ តាមអធ្យាស្រ័យ ។ ល ។ សមុទ្រ - តុទ្ធបក្រ... ។

| | | | |
|---|---|---|---|
| សមុទ្រ... | វីណា ស្រែត... | គាថី... | បញ្ញា... |
| ពុទ្ធបក្ក... | មរក្ខន ... | អម្ពុ... | បុញ្ញា ... |
| វត្ត, វត្តិយ... | ទក្ខិណា ... | បច្ឆិម... | សុញ្ញា ... |
| វេត្ត... | វេម... | បច្ចាមិត្ត... | កញ្ញា... |
| បុត្ត... | គហាល់ស... | អច្ឆរិយ... | អរញ្ញ... |
| អាយុវ័យ... | បរេក្ខ... | វិជ្ជា... | ទុព្ភិក្ខ... |
| អក្ខរៈ... | បច្ច័យ... | វេជ្ជ, វេជ្ជ... | ទាក្ខធម៌... |
| វណ្ណៈ... | បច្ចូសកាល... | វិជ្ជាធរ... | ចិត្ត ... |
| គន្ធបទ... | កិច្ច...... | មជ្ឈ ... | មិត្ត ... |
| វត្តី:: | ពាក្យសច្ច ... | មាណវ... | មជ្ឈិម ... |

## ៣៣- អាខ្វាក់អាខ្វិននាំគ្នាដើរ



មានមនុស្សពិការពីរនាក់ ម្នាក់ខ្វាក់ ម្នាក់ខ្វិន នៅជាផ្ទះគេទាំងពីរនាក់ ប៉ុន្តែម្ចាស់ផ្ទះឃ្លាតពីគ្នា ៗ គេប្រើឲ្យធ្វើការផតគាណាតមេត្តាសោះឡើយ ហើយបុរសទាំងពីរគិតថា: ទីនេះគេបណ្ដែងបំភើគេ ៗ លុះដល់យប់គេនាំគ្នាចុះទៅកំពង់ លួចទូកគេជិះចេញទៅពស្រ័យឈមមុរវល់គ្នាំប្រែងក្តុំ ៗ ខណៈនោះយប់ងងឹតមើលអ្វីមិនឃើញ ពាគិតស្មានថាទូកលឿនទៅមុខហើយ តែទូកនោះនៅ

វិលទៅយកនៅត្រង់កំពង់នោះដដែល ៗ លុះភ្លឺឡើងម្ចាស់ចុះមក ឃើញក៏ហៅឲ្យឡើងវិលទៅផ្ទះវិញ ៗ

នៅយូរបានបន្តិចមក អាខ្វាក់អាខ្វិនបបួលគ្នាដើរទៀត ហើយពិគ្រោះជាមុនថា: "យើងរត់លើកនេះ កុំឲ្យភ្លាស់យើងភាមពាន់ យើងទៅដើរគោកវិញ" អាខ្វាក់ឆ្លើយថា "ទៅប្ដូរម្ដងបាន បើសុខតែខ្វាក់ខ្វិនយ៉ាងនេះ" អាខ្វិនឆ្លើយឡើងថា "ឯងកុំព្រួយ ឯងទំរអញជិះលើឯង ហើយអញបង្ហាញផ្លូវឯង" លុះដល់យប់ស្ងាត់ អាខ្វាក់លីកអាខ្វិនដើរចេញទៅដល់ស្រុកមួយ អាខ្វិនប្រទះឃើញខ្ទមគេតាំងស្រែមួយ ហើយប្រាប់អាខ្វាក់ថា: "ខ្ញុំយកសំឡាញ់ មានខ្ទមមួយមានខ្សែពួរមួយបន្ទាយ ចង្កើរមួយ ទឹកអណ្ដែកមួយផង" អាខ្វាក់ថ្កុះហើយឆ្លើយថា: "អញ្ចឹងយកឲ្យអស់" ៗ អាខ្វិនថា: "យកធ្វើអ្វីជូនតែសំពៅ" អាខ្វាក់ថា: "ជូនអ្វីឯង ជូនតែអញទេ, បេះតែយកទៅ" អាខ្វាក់ក៏ប្រមូលយករបស់ទាំងអស់ ក្នុងខ្ទមនោះមានបាយមួយឆ្នាំងផង ដែលគេដាំទុកនៅដើរក្រានទាក់យកទាំងអស់ស្រេច

ហើយ គាត់វិនឡើងផ្ទះលើគោកខ្ពស់ទៀត ឯគោខ្ពក់ជាមនុស្សទាំងយក របស់ទាំងនោះទៅបាន ។

## ៣៤–សុភាទន្សាយបានសង្គ្រោះ

ត្រី – កំពឹស – ក្តាម – ខ្យង ឲ្យរួចជីវិត

ទន្សាយទៅដល់មាត់បឹង ឃើញសត្វទាំងឡាយកំពុងតែបាចទឹក ក៏បេះស្លឹកឈើដែលមានដង្កូវស៊ីមានស្នាមក្រវែងក្រវាមមកក្ដឹង ធ្វើជាសំបុត្រ ហើយស្រែកហៅសត្វទាំងឡាយនោះថា: "នែបងប្អូនទាំងអស់គ្នាស្ដាប់ខ្ញុំ ! ព្រោះព្រះឥន្ទ្រឲ្យខ្ញុំនាំសំបុត្រនេះមកប្រកាសប្រាប់អស់អ្នករាល់គ្នាថា: "ព្រះឥន្ទ្រលោកនឹងមក កាប់ដើមត្រី ឫស្សីនឹងដើមអក កាប់ក្បាលចចកដកក្រចកដំរីសារ កាប់ក្បាលគាខ្លាឲ្យស្រៀវៗចាំទេ វះពោះគាគេ កាត់កគាថ្ងាន់ ។ សត្វទាំងអស់ឮដូច្នោះភ័យណាស់ ផ្អើលទៅឡោះបោលជាន់លើគ្នា ដំរី ក្របី មាស រមាំង ខ្លា គេ ស្ទុះបោលទៅជាន់លើពស់



ក្ដាមដែលធ្វើជាទំនប់ ដាច់ខ្លួនជាពីរបីកំណាត់ ធ្លាយទឹកលិច

ស្លាប់អស់សត្វទាំងនោះទៅជាចំណីត្រីធំនិងអណ្ដើកវិញ ។

តាំងអំពីថ្ងៃនោះមកសត្វទាំងអស់សឹងតែកោតខ្លាចប្រាជ្ញាទន្សាយ

ហើយហៅថាសុភាទន្សាយទាំងអស់គ្នាអំពីថ្ងៃនោះមក ។



## ៣៥_វិជ្ជាសម្បត្តិ

វិទ្យាកុំផុនទាំងអស់គ្នា ចំណេះវិជ្ជាទាំងសម្ពាយ
មានគុណវិសេសដ៏ទូលាយ គួរយើងរៀបស្ពាយកុំខ្លាចធ្ងន់ ។
មិនលំបាកទុកស្រណុកណាក់ ជាជាងមាសប្រាក់សព្វទ្រព្យធន
មិនខ្លាចចោរលួចចោរប្លន់ ទៅគ្រប់ជម្ពូទ់គ្រាន់ជាស្បៀង ។
ឥតគេណ្តៀរគោរពគុណគាត់ ចាយណាស់មិនបាត់មិនមានស្អៀង
ប្រើច្រើនកើតច្រើនចំរើនទៀង ពីបច្ចុប្បន្នទៀងទៅបរលោក ។
មានសុវិជ្ជាគង់មានទ្រព្យ អ្នកផងមិនស្អប់មិត្តមូលមក
បានមិត្តហើយបុណ្យនឹងតេក រួចទៅបរលោកយានស្ពានឫទ្ធិ ។

## ៣៦ - នាងកង្រីថ្វាយសេចក្ដីស្ងាត់ កំបាំងដល់រថសេន

ប្រពាតសួនរួចហើយ ទៅដល់មុខទ្វារឃ្លាំងទឹកដូចបុប្ផានៅ ស្ងាត់ដាច់សន្លឹងឆ្ងាយពីកន្លែងដទៃ នាងកង្រីឈប់ស្ងាំងកាំងកាន់ គាំងស្មារតី ហើយភ័យណាស់ ទើបទូលស្វាមីថា: ឃ្លាំងនេះ មានការសម្ងាត់ មាតាខ្ញុំម្ចាស់ហាមផ្ដាច់មិនឲ្យប្រាប់អ្នកណាឲ្យដឹង ថាមានរបស់អ្វីៗនោះឡើយ ។

នាងរិតចូលទៅជិតស្វាមីហើយទូលថា: ក្នុងឃ្លាំងនេះ នៅលើតុមួយមានពានថ្លាក់មួយក្រឡាមាស ក្នុងពាននោះមានភ្នែកស្រីពីរដណ្ដប់ទាក់ ហើយនៅជិតពាននោះមានដបមួយ ក្នុងដបនោះមានថ្នាំដាក់ភ្នែកភ្ជាក់ឲ្យជាវិញ ។ បើអ្នកណាខ្វាក់ភ្នែកប្រេះប្រស្រះចេញ គ្រាន់តែដាក់គ្រាប់ភ្នែកក្នុងរន្ធទៅវិញហើយលាបថ្នាំនេះទៅ នោះភ្នែកនឹងជាឡើងហើយភ្លឺដូចដើមវិញហោង ។



រិទ្ធិសែនទាំងស្កាត់ព្រះទ័យគំពីសេចក្ដីទុក្ខសោក ហើយ ស្ដេចនាំនាងកន្ធ្រីវិលទៅប្រាសាទវិញរហោង ។

លុះដល់យប់ ពេលសោយក្រយាស្ងោយ រិទ្ធិសែនចាប់ផឹកស្រាទាំងកន្ធ្រី ហើយទីនពួកពលយក្សទាំងអស់ឲ្យស្រវឹងគ្រប់គ្នា លង់លោមឲ្យដេកលក់ទៅ ហើយលបយកគូនសោទ្វារឃុំនាងកន្ធ្រីបាន ។ ស្ដេចយាងទៅយកនំក្នុងទាំងពីរដណ្ដាប់ មកដបថ្នាំ ហើយទីនដំបងផង ។ ទើបស្ដេចយាងមកឧបបួម លានាង

ក្រពីដែលកំពុងដេកលក់មិនដឹងខ្លួនសោះនោះ រួចឡើងជិះសេះរត់ទៅ ។

## ៣៧ — សត្វទុងនឹងត្រី



មានសត្វទុងមួយ ជាសត្វកាន់សក្កាយទិដ្ឋិ ។ ថ្ងៃមួយក៏ចេញស្វែងរកចាប់ត្រីជាអាហារ ។ លុះហើរទៅបានឃើញត្រីក្អកមួយ នៅខាងមាត់ខ្លួន ទុងនោះក៏ចឹកត្រីក្អកនោះបាន ហើយមកគិតថា អាត្មាអញនេះជាបក្សីរូបធំ ត្រូវតែបរិភោគត្រីធំ ៗ យ៉ាងត្រីរ៉ស់ ត្រីឆ្តោ ត្រីប្រាជាដើម នោះទើបសមនឹងសក្តិយសរូបអញនេះ អាត្រីក្អករូបតូចមួយនេះមិនសមគួរនឹងរូបអញឡើយ គិតហើយទុងក៏លែងចោលបង់ ហើយហើរទៅមុខទៀត បានយល់ត្រីចង្វាភ្លៀងមួយ ទុងក៏ចឹកបានឡើងនឹងស៊ី ក៏គិតថា៖ ត្រីចង្វាភ្លៀងនេះតូចពេកណាស់ ពុំគួរនឹងរូបអញជាធំ គិតហើយ

គឺលែងត្រីនោះទៅលឿន ហើយទាំងហែលរឹតស្រួលទៅមុខទៀត ស្រួលទៅ ៗ គេត្រីពុំបាន ពេលនោះក៏ខំតាមល្បួងនឹងចុះពេល ស្រួល ទុំនោះឯង កើតក្តីឃ្លានអាហារមហិមា រីស្រួលរកអាហារ ពុំបានឡើយ ម្ល៉ោះហើយទុំក៏កតុក្ក មុខស្មុបស្មៅកើតក្តៅចិត្ត គិតស្តាយអាហារដែលខ្លួនរកបានអំពីត្រី ។

## ៣៨ – ស្ត្រីពីរនាក់ដណ្តើមកូនគ្នា

មានស្ត្រីពីរនាក់មានកូនដូចគ្នា ម្នាក់កូនទើបនឹងស្លាប់ទៅ ម្នាក់កូននៅរស់ហើយពកូនយកទៅងូតទឹក ។ ឯស្ត្រីកូនស្លាប់នោះ ដើរមកជួបហើយស្រដីថា: "កូននាងដូចកូនអញណាស់ នាងអើយ អញសូមបីបកូននាងបន្តិច" ។ នាងម្តាយក៏ឲ្យកូនទៅ ស្ត្រីនោះ ទទួលយកមកបីបបំពៅហើយយកកូនគេដើរទៅលំនៅខ្លួន ។ នាងម្តាយស្រែកហៅថា: "នាងអើយ ! នាងយកកូនអញទៅឯណា" ។ ស្ត្រីនោះតបថា: "កូនអញទេតើ ម្តេចក៏មេថាកូនមេ" ។ ម្ល៉ោះហើយ ឈ្លោះប្រកែកគ្នាទៅវិញទៅមក រួចនាំគ្នាទៅប្តឹងទៅក្រម ។



ចៅក្រមជំនុំពិភាក្សាកាត់សេចក្តីនេះពុំបាន ទើបនាំស្ត្រីទាំងពីរនោះឡើងទៅ ក្រាបទូលសម្តេចព្រះមហាក្សត្រ ជាក់ដោយនូវដំណើរនោះ ៗ ព្រះអង្គទ្រង់ជ្រាបសព្វគ្រប់ ហើយត្រាស់ឲ្យយកកូននោះទៅដាក់នៅទីកណ្តាលឲ្យដណ្តើមគ្នា ត្រាស់ថា: បើនរណាដណ្តើមបាន ឲ្យអ្នកនោះយកកូននោះចុះ ៗ

កាលបើដូច្នោះហើយ ស្ត្រីទាំងពីរចូលដណ្តើមគ្នា, ឯស្ត្រីស្លាប់កូន ចាប់ទាញយ៉ាងពុំគិតបាក់បែកហែកដៃជើង ឥតករុណាប្រណី

ជាកូនហើយ ៗ ឯម្ដាយយល់ឃើញមនោះជាទំពុះការប្រាប់កូន ចាប់ពុំគិតឡាក់បែកហើយកំលែងកូនឲ្យបាន ជាវៅ ៗ ទើបព្រះអង្គមានព្រះបន្ទូលត្រាស់ថា : ព្រោះប្ដូរលែងកូនឲ្យបានទៅគេនោះ ហេតុដូច្នេះគួរស្ដាយករុណាកូន ព្រោះស្ត្រីនោះឯងជាម្ដាយពិតមែន ៗ ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ទ្រង់កាត់សេចក្ដីឲ្យបានកូននេះទៅម្ដាយវិញ រីឯមេដណ្ដើមកូនគេនោះ ព្រះអង្គឲ្យផ្ដន្ទាទោស ៗ

## ៣៩ - រឿងខ្លាឃ្មុំនឹងដើមពន្រ

ខ្លាឃ្មុំមួយ ទៅដេកនៅក្រោមដើមពន្រ ១ ដើម លុះដេកលក់បន្តិចទៅ ផ្លែពន្រធ្លាក់មកត្រូវក្បាល ខ្លាឃ្មុំក៏ភ្ញាក់ក្រោកឡើងមិនមាបាន ក្ដីឈឺក្បាលពន់ពេកណាស់ក៏



ដើរចេញចាកទីនោះ ហើយទឹកចិត្តខឹងនឹងដើមពទ្រក៏ចងអាឃាត ។ គ្រាកាលនោះ មានអ្នករទេះម្នាក់បររទេះមកត្រង់ទីនោះ ជួនជាភ្លៅរទេះបាក់ក៏ឈប់ ហើយកាន់ពូថៅដើរចូលព្រៃ ដើម្បីនឹងកាប់ឈើធ្វើភ្លៅរទេះ ។ លុះដើរៗទៅបានជួបនឹងខ្លាឃ្មុំកណ្ដាលព្រៃ ។ ខ្លាឃ្មុំក៏សួរថាៈ អ្នកបងឯងដើររកអ្វី ចៅនោះក៏ប្រាប់ថាៈ យើងដើររកកាប់ឈើធ្វើភ្លៅរទេះ ខ្លាឃ្មុំបានឮក៏សើចប្រាប់ទៅថាៈ ឈើសម្រាប់ធ្វើភ្លៅរទេះ គ្មានឈើណាជាប់ស្វិតដូចដើមពទ្រទេ ចូរអ្នកឯង ទៅកាប់ដើមពទ្រឯណោះចុះ ។ អ្នករទេះក៏ចូលទៅកាប់ដើមពទ្រនោះ តាមខ្លាឃ្មុំប្រាប់ ។ ឯដើមពទ្រនោះជាលំនៅនៃរុក្ខទេវតា ។ កាលបើឃើញមនុស្សកាប់លំនៅខ្លួនដូច្នោះ ក៏ចេញមកសួរថា អ្នកកាប់ដើមពទ្រដើម្បីការអ្វី ? ចៅនោះប្រាប់ថាយកទៅធ្វើភ្លៅរទេះ ដ្បិតខ្លាឃ្មុំបានប្រាប់ថា ឈើនេះជាប់ល្អណាស់ ។ រុក្ខទេវតាដឹងថាខ្លាឃ្មុំចងគំនុំនឹងដើមពទ្រក៏ប្រាប់ថា បើបានខ្លាញ់ខ្លាឃ្មុំមកលាបនោះ ទើបស្វិតជាប់ល្អបរទៅសប្បាយ បើដូច្នេះចូរអ្នកឯងទៅសម្លាប់ខ្លាឃ្មុំយកខ្លាញ់វាទុកលាបភ្លៅរទេះអ្នកទៅ ។

## ៤០ – ឆ្មាស្រុកនឹងចាបពួក



ឆ្មាស្រុកមួយ ចាបពួកមួយ នៅជាមួយគ្នា ៗ ថ្ងៃមួយមានចាបព្រៃហើរមកទំ នៅជិតចាបពួកនោះ ហើយពោលពាក្យតិះដៀល ចាបនៅក្នុងទ្រុង ចាបក្នុងទ្រុងក៏កើតទោសឡើង ទើបជេរប្រទេចទៅចាបព្រៃវិញ ៗ ជម្លោះជេរគ្នាទៅវិញ ទៅមកក៏កើតឡើងតែនឹងបែកគ្នាពុំបាន ព្រោះមួយនៅក្នុងទ្រុង មួយនៅក្រៅទ្រុង ៗ ឯឆ្មាស្រុកបានឮចាបទាំងពីរឈ្លោះគ្នាដូច្នោះ ក៏វឹងហើយគិតថា "អាសត្វចង្រៃ ហេតុអ្វីមកឈ្លោះប្រកែកនឹងចាបជាសំឡាញ់អញអេះ, បើដូច្នេះអញនឹងជួយចាបជាសំឡាញ់ចុះ" ៗ គិតហើយឆ្មានោះចាប់ចាបព្រៃនោះបាន ហើយទំពាស៊ីជាចម្ងាញ់ ៗ "ឲ្យ! អញមិនដឹងថាសាច់ចាបព្រៃមានរសជាតិឆ្ងាញ់ដល់ម្ល៉េះសោះ បើដូច្នេះ ចាប់ផ្ដើមតាំងពីថ្ងៃនេះទៅ អញនឹងស្វែងចាប់ចាបព្រៃ

ស្រែយ... ៗ ឆ្មានោះគិតថាពិតហើយ ពីថ្ងៃនោះមកគាំងស្វែងលបចាប់ចាបត្រែកស្រែយ៉ាងទីរន្តរ ៗ ថ្ងៃមួយឆ្មានោះរកចាប់ចាបត្រែពុំបាន ដោយឃ្លានមាត់អត់ពុំបាន ក៏ហែកទ្រុងចូលទៅចាប់ចាបផាសំ ឡាញប់វិគោតតាមក្តីប្រាថ្នាហោង ៗ

## ៤១- ល្ពៅនឹងឬក់ទំពក់នៅដៃ

មានអមាត្យមួយនាក់ តែងរក្សាដើមល្ពៅព្រះរាជទ្រព្យព្រះមហាក្សត្រាធិរាជ គាត់រាប់ផ្លែល្ពៅនោះរៀងរាល់ថ្ងៃ បើមានផ្លែណាទុំគាត់បេះទៅថ្វាយស្តេច ៗ គាប់ជួនថ្ងៃមួយ មានបុរសម្នាក់យកទំពក់ទៅបេះផ្លែល្ពៅអំពីត្រែងទៀត ។ តែបុរសនោះលីទំពក់ដក់ផ្លែល្ពៅដើរទៅទៀបខាងដើមល្ពៅ អមាត្យមើលទៅឃើញបុរសនោះមានទំពក់នៅដៃ នឹងផ្លែល្ពៅនៅឬក់ ទើបគាត់ទៅរាប់ផ្លែល្ពៅរបស់គាត់មើល លុះពិនិត្យទៅឃើញខ្វះ ទើបគាត់គិតថា៖ នេះសមតែលីទំពក់បេះផ្លែល្ពៅនេះ ដក់ទៅអំបាញ់មិញនេះឯងជាពោលលួចបេះផ្លែល្ពៅស្តេចមិនខានឡើយ ៗ ទើបអមាត្យក៏តែទៅតាម



ចៅនោះ ឃើញផ្លែល្ពៅ ខាំចុកចំពក់នៅផង ហើយកោះយកទៅនោះទៅក្រាបទូលសម្ដេចព្រះមហាក្សត្រាធិរាជ ដោយដំណើរសព្វគ្រប់ ។ ព្រះអង្គមានព្រះបន្ទូលថាកុំគាល់តាមវាឡើយ ឲ្យយកផ្លែល្ពៅនោះទៅផ្សាប់ទីដដែល បើវាត្រូវឲ្យចំណាក់តំពក់នឹងនោះមកដីមើល វាជ្រុះទៅត្រង់ណាឲ្យពិចារណាតាមដោយខ្លួនហេតុនោះហោង ។

អមាត្យយកផ្លែត្នោតទៅផ្គាប់នឹងទងនោះមិនត្រូវឡើយ ព្រះអង្គបង្គាប់ឲ្យទំលាក់មកដី ផ្លែត្នោតជ្រុះទៅក្នុងថ្លុកកក់ រួចព្រះអង្គឲ្យគាយកក់យកផ្លែត្នោតនោះមកវិញ ។ ព្រះអង្គឲ្យយកផ្លែត្នោតជ្រុះពីថ្ងៃមុននោះទៅផ្គាប់នឹងទងដដែល មើលឃើញត្រូវមែន ទើបទ្រង់ព្រះរាជទានផ្លែត្នោតដែលដក់ទៅទៅនោះវិញ បុរសនោះក៏ក្រាបលាយករំពត់ទីងផ្លែត្នោតទៅបំនៅតាត្នោ ។

## ៤២- រឿងសត្វបក្សី

មានសត្វបក្សីមួយ អាស្រ័យនៅលើខ្លោងទ្វារព្រះរាជវាំងនៃព្រះបាទវិទេហរាស្ត្រ នៅក្នុងនគរមិថិលា បក្សីនោះបានឃើញស្តេចយាងចេញចូលតាមទ្វារនោះកាលណា ក៏ចុះមកដើរធ្វើសរសើផ្ទក់ៗ គឺគំនាប់គោរពព្រះបរមរាជាតែរាល់ៗ កាល ។ ឯព្រះបាទវិទេហរាស្ត្រ ស្តេចយល់អាការកិរិយាបក្សីនោះហើយ ក៏ត្រាស់សួរទៅមហោសថបណ្ឌិតពោធិសត្វ ក្រាបទូលតាមហេតុដែលបក្សីនុះបង្គំចំពោះបរមរាជា ទើបស្តេចមានព្រះហឫទ័យ

ក្រគរនឹងបណ្ឌ័យនោះឯង ហើយទ្រង់ប្រោសប្រាណព្រះកជតាន មាសមួយពែក្តាម បើកឲ្យនាយពិសេសទិញសាច់ឲ្យបណ្ឌ័យ ការស្រ័យតាមកាលសម័យពីថ្ងៃនោះមក ឯបណ្ឌ័យក៏បាននៅសុខសប្បាយពុំបានខ្វល់ខ្វាយចេញទៅស្វែងរកអាហារឯណាឡើយ ។

## ៤៣ -- អទិន្នបុព្វកៈ

មានព្រាហ្មណ៍ម្នាក់ឈ្មោះអទិន្នបុព្វកៈ នៅក្នុងនគរសាវត្ថី ។ បានជាឈ្មោះដូច្នេះដោយហេតុថា ព្រាហ្មណ៍នោះជាមនុស្សកំណាញ់ កាញ់សម្បត្តិខ្លួន មិនដែលបរិច្ចាគទ្រព្យ ចេញធ្វើបុណ្យឲ្យទាន ដល់សមណព្រាហ្មណ៍ និងសូម្បីយាចកទាំងឡាយឡើយ ។ ព្រាហ្មណ៍នោះមានកូនប្រុសម្នាក់ឈ្មោះមដ្ឋកុណ្ឌលី បានជាមានឈ្មោះដូច្នេះព្រោះកូននោះចំរើនធំឡើងហើយ អទិន្នបុព្វកព្រាហ្មណ៍ជាបិតាប្រាថ្នានឹងធ្វើកុណ្ឌលជាគ្រឿងបំពាក់ឲ្យនោះនឹងទៅជួលជាងទងធ្វើក្រែងអស់ថ្លៃឈ្នួល ទើបព្រាហ្មណ៍យកមាសមកដំដោយខ្លួនឯងធ្វើកុណ្ឌល ។ លុះចំណេរមក មដ្ឋកុណ្ឌលី

នោះមានផ្លែឈើ គឺកេតលឿង ។ ទើបនាងព្រាហ្មណីនិយាយនឹងប្ដីថាៈ អ្នកអោយកូនយើងស្គម កើតលឿងឈឺរ៉ៃយ៉ាងនេះ គួរអ្នកទៅរកគ្រូពេទ្យមកមើលមករក្សា, ឯព្រាហ្មណ៍ជាអ្នកខ្លាចបង់ខាតសម្បត្តិ ក៏ធ្វើព្រងើយកន្តើយមិនអើពើក្នុងការរកគ្រូមករក្សាកូនឡើយ ។ ឯកេតកូននោះរឹងរិតតែឈឺធ្ងន់ឡើង ព្រាហ្មណ៍យល់អាការកេតកូនកាន់តែឈឺធ្ងន់ ទើបគិតថា « កូនអញនឹងទុកឲ្យនៅក្នុងផ្ទះនេះយល់ថាពុំបាន ព្រោះពួកញាតិមិត្តទាំងឡាយគេចូលមកសួរជម្ងឺ គេនឹងឃើញទ្រព្យសម្បត្តិអញហើយ គេនឹងមកកូនរួបសុំអញ » ។ ព្រាហ្មណ៍នឹងប្រពន្ធនាំគ្នាសែងគ្រែកូនចេញមកដាក់នៅរានហាលផ្ទះ ។ ឯចៅមដ្ឋកុណ្ឌលីកុមារនោះលុះកេតក៏រឹតខ្លាំងឡើងហើយ ក៏ដល់នូវកាលកិរិយាក្នុងពួងកាលនោះហោង ។

# ៤៤ - ស្ទូចត្រី

គូកនពីរនាក់ គឹមនិងសាន រៀននៅសាលាជាមួយគ្នា



ឆ្លៀតឱកាសថ្ងៃព្រហស្បតិ៍ ក៏ទៅស្ទូចត្រី នៅមាត់ស្ទឹងសែន ។ លុះព្រឹកឡើងក៏ នាំគ្នាចេញទៅពីព្រលឹម ដ៏មាន សម្លៀកបំពាក់ចាស់ៗ មួកធំដើម្បីហ៊ុំនឹង ចំហាយព្រះអាទិត្យផង ។ ចៅគឹមលីដងសន្ទូចមួយ ដ៏មានខ្សែថ្មី សន្ទូចក៏ស្រួលខ្ទឹងប្រអប់ស៊ីវិឡាតដាក់នុយ ។ ចៅសានកាន់ល្អី ស្បៀងអាហារ ។ ក្មេងទាំងពីរនាក់ទៅឈប់នៅកន្លែងមួយ នាមាត់ទឹកដ៏មានម្លប់ល្អ ក៏ស្ទូចនៅទីនោះ ។ ដំបូងគ្មានត្រីមកស៊ីសោះ គឹមនិងសានពុំកំរើកខ្លួនឡើយ ។ ក្រោយត្រីផ្អើល ៗ មួយស្របក់ មានត្រីច្រើនហែលហែលនាក្នុងទឹក ។ កំសួលសន្ទូចក៏ញ្ញោល ឡើងម្ដងៗ ពីត្រីស៊ីសន្ទូចរាក់ផងសន្ទូចឡើងបានត្រី ។ មិនយូរ

ប៉ុន្មានវាបានតែពេញត្រកវាសប្បាយចិត្តក៏នាំគ្នាត្រឡប់ទៅផ្ទះវិញ ។ ម្ដាយវាទាំងពីរនាក់ក៏មានសេចក្ដីរីករាយ ហើយយកត្រីធ្វើម្ហូបស៊ីបាយ ។

## ៤៥- ផ្លែមង្ឃុត

សាន ទឹន ខុំ កាន់ដៃគ្នាដើរលេង ។ ដើរបានបន្តិចទៅក



ប្រទះផ្លែមង្ឃុតមួយនាកណ្ដាលផ្លូវ ។ សាននិយាយថា៖ ផ្លែមង្ឃុតនេះត្រូវបានអញព្រោះអញបានឃើញមុន ។ ខុំថាត្រូវបានអញទេ ព្រោះអញរើសបាន ។ ក្មេងទាំងពីរនាក់ចេះតែជជែកទៀបតែប្រវាយប្រតប់គ្នា ។ មានក្មេងម្នាក់ទៀត ឈ្មោះសារី មកដល់ទីនោះ វាឈរនៅចន្លោះក្មេងទាំងពីរ ហើយសួរគេដើមហេតុ រួចក៏យកកាំបិតបត់ពីហោប៉ៅអាវ ពុះមង្ឃុតជាពីរ

ហើយនិយាយថា៖ សំបកមង្ឃុតមួយចំហៀងនេះ ត្រូវបានទៅខាង ដែលបានឃើញមុន ឯសំបកមួយចំហៀងនេះទៀត ត្រូវបានទៅខ្ញុំ ដែលបានរើស, រីខ្លួនអញ ដូចជាគេថា តែធ្វើការអ្វីត្រូវមានឈ្នួល, បើដូច្នេះ អញត្រូវបានសាច់ ជារ្វប ហើយ ស៊ីតមសាច់មង្ឃុតទៅៗ

## ៤៦ – ដេញចាប់ចោរ ៗ ចាប់វិញ



បុរសមួយនាក់ដេកលើសាលា ៗ ឃើញចោរម្នាក់លួចគោគេ

ដេញល្បូទៅ ៗ បុរសដេកលើសាលា ក៏ស្ទុះលោតចុះទៅចាប់បានតាចោរ ៗ លុះម្ចាស់គោតាមទៅទាន់ តាចោរស្រដីប្រាប់ទៅថា: ចៅនេះឯងលួចគោអ្នក ៗ ឯបុរសដេកលើសាលាឆ្លើយទៀតថា: ចៅឯងលួចគោគេអញចាប់ចៅឯងបាន ម្តេចចៅមកថាអញវិញ ៗ ម្ចាស់គោយល់ថាប្រកែកគ្នាផុតផ្ទោះ ហើយទើបចាប់តែម្នាក់ឯងខ្លាចក្រែងពុំមែនចោរនោះ ទើបចាប់មនុស្សទាំងពីរទៅប្តឹងចៅក្រមឲ្យជំនុំជំរះ តាមពាក្យបណ្តឹងទាំងសងខាង ៗ ចៅក្រមពិចារណាកាត់សេចក្តីនោះពុំបានឡើយ ក៏នាំទៀងទៅក្រាបទូលក្សត្រាធិរាជដោយដំណើរនោះ ៗ ព្រះអង្គទ្រង់ព្រះចិន្តាត្រាស់បង្គាប់ឲ្យយកមនុស្សទាំងពីរនាក់នេះទៅចងឲ្យមូសខាំ ហើយឲ្យអមាត្យទៅលបចាំស្តាប់ពាក្យចៅទាំងពីរនោះ ៗ ចៅដែលដេកលើសាលាពោលរអ៊ូថា: បងតែឯង លួចគោគេទើបគេចងអញឲ្យមូសខាំ ៗ តាចោរថាអញលួចតែអញ ហេតុអ្វីក៏ចៅចាប់អញ

ព្រោះតែចាប់អញ ទើបគេបានអញមក អមាត្យកត់ពាក្យចៅទាំងពីរនោះ ហើយនាំឡើងទៅថ្វាយក្សត្រាធិរាជ ព្រះអង្គបង្គាប់ឲ្យពិន័យតាចោរមួយជាបួន គឺយកទ្រព្យដើមចេញ ហើយចែកក្រយាពិន័យជាភាគបី ភាគមួយបានទៅម្ចាស់គោ ភាគពីរបានទៅចៅដែលចាប់បានខ្លួនចោរនោះ ។

ការផ្សាយរបស់

បណ្ណាគារ គិម សេង

លេខ ២២៣ វិថីព្រះមុនីវង្ស

ភ្នំពេញ

ពូច - អ៊ុម

# វេយ្យាករណ៍ខ្មែរ



សំរាប់

## ថ្នាក់ បឋមសិក្សា